មជ្ឈមណ្ឌលឯកសារកម្ពុជា

# សម្ភាសន៍ជាមួយឈ្មោះ សួន ម៉ុត ភេទប្រុស អាយុ៦៥ឆ្នាំ

**មុខងារសម័យខ្មែរក្រហមៈប្រធានភូមិថ្មី ឃុំខ្លៀត ស្រុកសេរីសោភ័ណ្ឌ តំបន់៥**

**ស្រុកកំណើតនៅភូមិស្រែជា ឃុំសំឡាញ ស្រុកអង្គរជ័យ ខេត្តកំពត**

**សព្វថ្ងៃរស់នៅភូមិទួលខ្ពស់ ឃុំភ្នំព្រឹក ស្រុកភ្នំព្រឹក ខេត្តបាត់ដំបង**

**ថ្ងៃទី៨ ខែសីហា ឆ្នាំ២០១៤**

**សម្ភាសន៍ដោយៈ ឡុង ដានី**

**០១:៣៤:១៣**

**៣៨ទំព័រ**

ដានីៈ ដំបូងខ្ញុំចង់ស្គាល់ឈ្មោះលោកពូមួយសារទៀត ប៊ុនថន បានស្គាល់លោកពូហើយ ។

ម៉ុតៈ សួន ម៉ុត ។

ដានីៈ លោកពូអាយុប៉ុន្មានហើយ?

ម៉ុតៈ ខ្ញុំរាល់ថ្ងៃអាយុ៦៥ឆ្នាំ ។

ដានីៈ ស្រុកកំណើតជានៅណាដែលលោកពូ?

ម៉ុតៈ ស្រុកកំណើតកើតជានៅភូមិស្រែជា ឃុំសំឡាញ ស្រុកអង្គរជ័យ ខេត្តកំពត ។

ដានីៈ ឃុំសំឡាញ?

ម៉ុតៈ បាទ!

ដានីៈ ហើយគ្រួសារលោកពូគាត់ឈ្មោះអី?

ម៉ុតៈ សោ វ៉ែន ។

ដានីៈ គាត់អាយុប៉ុន្មានដែរ?

ម៉ុតៈ បងខ្ញុំ ដូចជា៦៨ហើយ ។

ដានីៈ អាយុបងលោកពូ៣ឆ្នាំ ។

ម៉ុតៈ ៦៧ បងខ្ញុំ២ឆ្នាំ ។

ដានីៈ គាត់អ្នកស្រុកកំណើតនៅណាដែរ?

ម៉ុតៈ ស្រុកកំណើតនៅជាមួយគ្នា ជីដូនមួយ ។

ដានីៈ បាទ! ចាស់ៗពីមុនច្រើនតែជាប់សាច់ឈាមគ្នា ។

ម៉ុតៈ ចាស់ទុំផ្សំផ្គុំឲ្យ ។

ដានីៈ លោកពូរៀបការតាំងពីឆ្នាំណាមក?

ម៉ុតៈ ឆ្នាំ១៩៧១ ។

Documentation Center of Cambodia
Searching for the Truth: Memory & Justice ស្វែងរកការពិត ដើម្បីការចងចាំនិងយុត្តិធម៌
66 Preah Sihanouk Blvd. • P.O.Box 1110 • Phnom Penh • Cambodia
t (855-23) 211-875 • f (855-23) 210-358 • dccam@online.com.kh • www.dccam.org

ដានី: លោកពូមានកូនចៅប៉ុន្មាននាក់ដែរ?

ម៉ុត: កូនខ្ញុំ៥នាក់ ប្រុស៤ ស្រី១ ។

ដានី: ធំៗអស់ហើយ?

ម៉ុត: ការហើយអស់ហើយ ចៅ ។

ដានី: មានចៅធំៗ?

ម៉ុត: ចៅកំលោះក្រមុំអស់ ។

ដានី: លោកតា លោកយាយឈ្មោះអីដែរ? ឪពុករបស់អ៊ំ?

ម៉ុត: ឪពុកខ្ញុំ?

ដានី: បាទ!

ម៉ុត: ឪពុកខ្ញុំឈ្មោះកែវ សៀង ។

ដានី: ឈ្មោះ កែវ សៀង ។

ម៉ុត: ស្លាប់បាត់ហើយតាំងពី៧៧គេយកទៅវៃចោល ។

ដានី: អាពតីង?

ម៉ុត: បាទ!

ដានី: កែវ សៀង?

ម៉ុត: កែវ សៀង ។

ដានី: អាពតីងឆ្នាំ៧៧គេយកទៅវៃចោល?

ម៉ុត: គេចាប់យកទៅដាក់ឃុំឃាំង ដល់ហើយយកវៃចោល ។

ដានី: ម៉េចគាត់ខុសអីបានគេធ្វើអាពតីង?

ម៉ុត: អត់មានខុសអីតាមអ្នកស្រុកនិយាយ គាត់ឃ្វាលដីរ៉ៃ គេឲ្យគាត់ឃ្វាលដីរ៉ៃគាត់ធ្វើសង្គមកិច្ចស្រុកភូមិ ដល់ពេលអាពតីងទៅ កម្មាភិបាលគុំគួនគ្នា គាត់ធ្វើការល្អខាងមេឲ្យគាត់ធ្វើការស្រួល ។ មិនស្រួលអីគាត់ឃ្វាលដីរ៉ៃ៣-៤នោះតែឯងហ្នឹង ដល់ពេលសុំគេមកលេងផ្ទះកូនចៅ គាត់នៅឆ្ងាយ ដល់ហើយចងដីរ៉ៃស៊ីស្រូវអស់តិចហ្នឹងគេចោទគាត់ថាខ្មាំង ហ្នឹងយើងដឹង ។

ដានី: គាត់ធ្វើធំដែល? ខាងសង្គមកិច្ចស្រុកម៉េចគេចោទគាត់?

ម៉ុត: គាត់អតីតជំទប់លេខ១ជំនាន់រដ្ឋកម្ពុជា ។

ដានី: ជំនាន់លន់ នល់?

ម៉ុត: ខ្ញុំស្លាប់អស់២ មាមួយប្អូនគាត់បង្កើតគេវៃចោល ហ្នឹងគេវៃចោលឆ្នាំ៧៣ ។

ដានី: ចុះម្ដាយលោកពូគាត់ឈ្មោះអី?

មុំតៈ ម្ដាយ វង មៃ គាត់ទើបតែស្លាប់ឥឡូវនេះ ស្លាប់ឆ្នាំ៧២ ។

ដានីៈ ៧២ ឬ៨២?

មុំតៈ ដែល២០១២ ។

ដានីៈ ទើបឥឡូវប៉ុន្មានឆ្នាំ?

មុំតៈ បាទ!

ដានីៈ ២០១២នេះទេ? ២ឆ្នាំមុននេះ?

មុំតៈ បាទ! គាត់អាយុ៨២ ។

ដានីៈ លោកពូមានបងប្អូនបង្កើតប៉ុន្មាននាក់?

មុំតៈ ៣នាក់ ប្រុស២ ស្រី១ ។

ដានីៈ តែ៣នាក់?

មុំតៈ បាទ!

ដានីៈ សព្វថ្ងៃគាត់នៅស្រុកកំណើតឬនៅនេះ?

មុំតៈ នៅនេះជាមួយគ្នា ។

ដានីៈ នៅនេះទាំងអស់គ្នា?

មុំតៈ នៅនេះ២នាក់ នៅភូមិបារាំងធ្លាក់ម្នាក់ ។

ដានីៈ នៅភូមិ?

មុំតៈ មេប៉ុស្ដិ៍នៅភូមិបារាំងធ្លាក់ ។

ដានីៈ នៅភូមិបារាំងធ្លាក់ក្នុងស្រុកភ្នំព្រឹកដែរ ។

មុំតៈ បាទ! ជាប់គ្នាភូមិបារាំងធ្លាក់ ។

ដានីៈ អីចឹងសព្វថ្ងៃលោកពូរស់នៅក្នុងភូមិ ភូមិអីភូមិនេះ?

មុំតៈ ភូមិទួលខ្ពស់ ឃុំភ្នំព្រឹក ស្រុកភ្នំព្រឹក ។

ដានីៈ ឃុំភ្នំព្រឹក ស្រុកភ្នំព្រឹក ហើយបងប្អូននៅនេះទាំងអស់?

មុំតៈ បាទ!

ដានីៈ លោកពូកាលពីក្មេងៗរៀនសូត្រដល់ណាដែរ?

មុំតៈ ខ្ញុំរៀនដល់ថ្នាក់ទី៨ ខ្ញុំឈប់តាំងពីឆ្នាំ៦៦ ។

ដានីៈ ឈប់ឆ្នាំ៦៦?

មុំតៈ បាទ!

ដានីៈ មេ៉ចបាន?

ម៉ុត:	ខ្ញុំឈប់ម្ដាយខ្ញុំគាត់ទីទ័លដៃជើង ខ្ញុំបងគេ ប្អូនតូចៗ ហើយម្ដាយខ្ញុំ ឪខ្ញុំគាត់លែងលះគ្នាតាំងពីឆ្នាំ៦៣ គាត់មានប្រពន្ធចុងទៀត តែនៅតែរាប់អានគ្នាដល់៦៦ម៉ែខ្ញុំលំបាកពេក ខ្ញុំឈប់រៀន យាយ-តាអត់ឲ្យឈប់តែខ្ញុំឈប់ ធ្វើស្រែ ។

ដានី:	កាលរៀនៗនៅណា? រៀននៅសាលាស្រែជា?

ម៉ុត:	នៅសាលារៀនវត្តស្រែជា ។

ដានី:	ហើយឆ្នាំ៦៦ឈប់ទៅអុំធ្វើអីទៅ?

ម៉ុត:	ធ្វើស្រែ ពេលចប់រដូវធ្វើស្រែ អារឈើ ពីដើមអាររណាចាស់យើង ដូនកាលទៅចាក់បៀរយែរ(Beer) ។

ដានី:	អារឈើអារនៅណា?

ម៉ុត:	អារឈើនៅតាមស្រុកភូមិគេដួល ។

ដានី:	កាលនៅក្មេងយើងចេះអារដែរ?

ម៉ុត:	ចេះខ្ញុំរៀនពីតា អាយុ១៦កាលនោះ ។

ដានី:	ដោយសារធ្វើស្រែ អារឈើ រៀនចាក់បៀយ៉ែរ(Beer) ដល់ឆ្នាំណាបានឈប់?

ម៉ុត:	ដល់ឆ្នាំ៧០ ធ្វើរដ្ឋប្រហារ លន់ នល់ធ្វើរដ្ឋប្រហារខ្ញុំឈប់ ។

ដានី:	ដល់ពេលលន់នល់ ធ្វើរដ្ឋប្រហារឈប់ ឈប់ទៅធ្វើអី?

ម៉ុត:	ឈប់អត់មានធ្វើអីនៅផ្ទះ នៅនេះអីចឹងគេកេណ្ឌចាប់ធ្វើទាហាន រត់ បួសវត្តបាន៦ខែ ធ្វើទាហានលន់នល់ កាលហ្នឹងវាចូលអត់ដល់វត្តខ្ញុំទេ តែគេកេណ្ឌចាប់មុនហ្នឹង ម៉ែពីដើមខ្លាចកូនគេហៅធ្វើទាហាន គាត់ឲ្យទៅបួស បួសបាន៦ខែសឹកវិញ សឹកវិញនៅយុវជនក្នុងភូមិ ។

ដានី:	ចូលធ្វើយុវជន?

ម៉ុត:	យុវជនភូមិ ។

ដានី:	យុវជនភូមិស្រែជាហ្នឹង?

ម៉ុត:	បាទ!

ដានី:	កាលហ្នឹងយើងយុវជនឲ្យខាងរំដោះ?

ម៉ុត:	ខាងជីរំដោះ ។

ដានី:	ខាងខ្មែរក្រហម?

ម៉ុត:	បាទ! ហើយនៅបាន១ឆ្នាំបានរៀបអាពាហ៍ពិពាហ៍ ។

ដានី:	រៀបអាពាហ៍ពិពាហ៍កាលហ្នឹងរៀបអាពាហ៍ពិពាហ៍អាយុប៉ុន្មានទៅ?

ម៉ុត:	អាយុ២១ ។

ដានី៖ ដល់ពេលលោកអ៊ំរៀបអាពាហ៍ពិពាហ៍ហើយធ្វើអីទៀតទៅ?

ម៉ុត៖ គេឲ្យធ្វើមេឃុំ កាលហ្នឹងមានក្រុមប្រវាស់ដៃ គេធ្វើដូច១០គ្រួសារគេឲ្យធ្វើស្រែប្រវាស់គ្នា ។

ដានី៖ កាលហ្នឹងពេលដែលរំដោះហើយ ពេលដែលលន់ នល់ ធ្វើរដ្ឋប្រហារឆ្នាំ៧០នៅក្នុងដីរំដោះហើយ?

ម៉ុត៖ បាទ!

ដានី៖ អីចឹងកាលហ្នឹងក្នុងស្រុកអង្គរជ័យខាងខ្មែរក្រហមគ្រប់គ្រងដែរ?

ម៉ុត៖ អត់ទេ គ្រប់គ្រងបានមួយកំណាត់ទេ បើពីស្រុកតាមថ្នល់ជាតិលន់ នល់គ្រប់គ្រងទេ ទាហានលន់ នល់គ្រប់គ្រង ដល់ឆ្នាំ៧៣បានវៃរំដោះបាន ។

ដានី៖ ប៉ុន្តែពីឆ្នាំ៧០មក គណៈស្រុកខាងខ្មែរក្រហមគេមានរៀបចំ មានគណៈស្រុកហើយ?

ម៉ុត៖ មាន ។

ដានី៖ គេហៅអង្គរជ័យអីចឹង ឬមានលេខ?

ម៉ុត៖ ហ្នឹងហើយគេហៅគណៈស្រុកអង្គរជ័យ កាលហ្នឹងមានឈ្មោះតានិន ។

ដានី៖ តានិន គាត់ធ្វើគណៈស្រុក?

ម៉ុត៖ បាទ! តែតានិន គេសម្លាប់គាត់ចោលតាំងពីឆ្នាំ៧៣-៧៤ ។

ដានី៖ គណៈស្រុក ម៉េចបានគេសម្លាប់គាត់ឆ្នាំ៧៣-៧៤?

ម៉ុត៖ គេចោទគ្នា ចោទថាខ្មាំង កាហ្សេបេ ។

ដានី៖ ពីណាគេដែលធ្វើការជាមួយគាត់?

ម៉ុត៖ មានតានិន ខ្ញុំស្គាល់ច្បាស់តែតានិន គាត់ខស្សព្វាហ៍មកប្រជុំនៅភូមិខ្ញុំ ។

ដានី៖ ហើយដល់ពេលលោកពូធ្វើមេក្រុមដល់ឆ្នាំណា?

ម៉ុត៖ ដល់ឆ្នាំ៧៣ហ្នឹងឯង ៧៣បានគេឲ្យធ្វើមេឃុំ សមាជិកគេ មេឃុំរហូត ។

ដានី៖ មេឃុំស្រែជា?

ម៉ុត៖ បាទ!

ដានី៖ ហើយដល់ឆ្នាំ៧៣ តានិន ហ្នឹងគេសម្លាប់ពីណាគេមកជំនួសគាត់ ។

ម៉ុត៖ តាញៀន-យាយថែម ។

ដានី៖ តាញៀនប្តីយាយថែម?

ម៉ុត៖ បាទ!

ដានី៖ តាញៀន គាត់មកធ្វើគណៈស្រុក?

ម៉ុត៖ ធ្វើគណៈស្រុកហ្នឹងរហូត ហើយយាយថែម គាត់គណៈតំបន់១៣ កាលហ្នឹងហៅតំបន់១៣ ។

ដានី:	តាញ៉ែន គាត់មកគណៈស្រុក តែយាយថែមគាត់អត់មកទេ?

ម៉ុត:	យាយថែមមក តែគាត់នៅកាន់តំបន់ ។

ដានី:	តាំងពីឆ្នាំ៧៣មក?

ម៉ុត:	តាំងពី៧៣រហូតដល់៧៥ ។

ដានី:	អីចឹងតាញ៉ែន គាត់មកធ្វើគណៈស្រុក យាយថែម គាត់មកនៅហ្នឹងដែរ?

ម៉ុត:	បាទ! នៅហ្នឹងដែរ គ្រាន់តែស្នាក់នៅជាមួយគ្រួសារគាត់ហ្នឹង តែដល់ពេលគាត់ចេញធ្វើការទៅតាមតំបន់ តាមស្រុក ។

ដានី:	យាយថែម គាត់តួនាទីធំជាងតាញ៉ែន?

ម៉ុត:	បាទ! ធំជាង ។

ដានី:	យាយថែម គាត់ស្នាក់នៅអន្លុងវែងជាមួយតាញ៉ែន ដែរ?

ម៉ុត:	បាទ! ជួនកាលគាត់ស្នាក់នៅតាកែវ នៅស្រុកជើងគ្រាំកក់ កាលហ្នឹងគេហៅមន្ទីរ មន្ទីរមានច្រើនណាស់ មន្ទីរតំបន់គេធ្វើនៅគ្រប់កន្លែង គ្រប់ស្រុក ។

ដានី:	ខ្ញុំធ្លាប់ទៅជួបតាញ៉ែន ដែរតែគាត់ដូចអត់សូវនិយាយអីជងហ្នឹង ។

ម៉ុត:	តាហ្នឹងកាលនៅគាត់ក្មេងនិយាយគ្រាន់បើ ដល់ចាស់អត់និយាយ គាត់រាងមាំងៗ ។

ដានី:	ម៉េចអីចឹង? តែកាលគាត់ធ្វើគណៈស្រុកគាត់និយាយដែរ?

ម៉ុត:	គាត់និយាយច្រើនដែរ ។

ដានី:	ខ្ញុំទៅជួបគាត់ដូចអត់មាត់?

ម៉ុត:	គាត់មាំងៗ គាត់ឈឺខ្វាំងពេក គាត់ឈឺតាំងពីជំនាន់ ចុះសុទ្ធតែអ្នកតស៊ូនៅព្រៃឆ្នាំ៦៨ ។

ដានី:	ហើយអ៊ំស្គាល់គាត់ច្បាស់ដែរ?

ម៉ុត:	ស្គាល់ច្បាស់ ចុះនៅទាហាន គាត់មានមន្ទីរតំបន់នៅក្រោយភូមិខ្ញុំ ក្រោយផ្ទះខ្ញុំ ។

ដានី:	អីចឹងមន្ទីរតំបន់នៅក្រោយផ្ទះ?

ម៉ុត:	កាលឆ្នាំ៧៣-៧៤ធ្វើមន្ទីរតំបន់ក្រោយផ្ទះខ្ញុំ ។

ដានី:	ហ្នឹងមន្ទីរតំបន់លេខប៉ុន្មាន?

ម៉ុត:	តំបន់១៣ ។

ដានី:	តំបន់១៣តែម្តង?

ម៉ុត:	បាទ! តែធ្វើច្រើនកន្លែងណាស់ ខ្លាចកបាល់ហោះទម្លាក់ ។

ដានី:	តែគណៈតំបន់១៣មិនមែនតែយាយថែមទេ?

ម៉ុត:	មិនមែនទេ តាមុត ។

ដានី: តាមុត យើង?

ម៉ុត: ហ្នឹងហើយ តាមុត, តាសោម ។

ដានី: ហើយយាយចែមនៅក្នុងគណៈតំបន់ហ្នឹងដែរ?

ម៉ុត: បាទ!

ដានី: តាមុត, តាសោម, យាយចែម តែ៣នាក់ហ្នឹង?

ម៉ុត: ហើយច្រើនណាស់សាខាគាត់ ស្អីៗខ្លះមិនសូវស្គាល់ មេធំៗជំនាន់ហ្នឹងខ្ញុំអត់សូវឃើញមុខបានមកប្រជុំម្តងៗ?

ដានី: ដល់ពេលបែកឆ្នាំ៧៥?

ម៉ុត: ៧៥ហ្នឹងយាយចែម ដល់ឆ្នាំ៧៦តាម៉ុក ចាត់តាំងឲ្យមកហើយ ឲ្យយាយចែមគណៈតំបន់នាំកំលាំងមកទាំងប្រជាជន ទាំងមេភូមិ ឲ្យទៅនៅពាយ័ព្យ បាត់ដំបង ៧៦ ។

ដានី: អ៊ីចឹងពេលដែលបែកភ្នំពេញ៧៥ហើយ ពេលដែលខាងខ្មែរក្រហមគ្រប់គ្រងទូទាំងប្រទេសហើយកាលហ្នឹងឆ្នាំ៧៥លោកពូនៅជា?

ម៉ុត: មេភូមិ តែចាត់តាំងគេឲ្យខ្ញុំមកជីកប្រឡាយនៅម្តុំកោះអណ្តែត ខ្ញុំចុះរហូតតាំងពីរំដោះហើយអត់ដែលនៅផ្ទះទេ ប្រវត្តិអត់ដែលជួប បានមកជួបគ្នាឆ្នាំ៧៥ ។

ដានី: អ៊ីចឹងនៅឆ្នាំ៧៥ហ្នឹង ខ្ញុំបកទៅខាងក្រោយបន្តិច លោកពូកាលនៅស្រែជាជំនាន់ឆ្នាំហុកជាងចិតជាង ខាងពួកវៀតកុងមកច្រើនទេ នៅចាំ?

ម៉ុត: អត់ដែលឃើញទេ ពួកវៀតកុងកាលជំនាន់ហ្នឹងច្រើននៅព្រៃ អត់ដែលឃើញ នៅព្រំដែននៅខាងតាកែវ ក្បែរមាត់សមុទ្រពីដើមនៅក្បែរព្រំដែនយួនខាងត្បូង នៅស្នាក់នៅហ្នឹងឯងហ្នឹងខ្ញុំសួរចាស់ៗដែលពូខ្ញុំទៅរកត្រី កាលហ្នឹងព្រំដែនយួន-ខ្មែរយើងពីដើមសំបូរត្រីណាស់ កាលហ្នឹងទៅជួបសុទ្ធតែយួនយៀកុង ថ្ងៃឡើងស្ងាត់ឈឹង តែដើរមិនស្រួលជាន់នៅកម្ពុតព្រៃតែពីដើមសុទ្ធតែព្រៃ ដើមកោងកាង ម្រះព្រៃ ហើយស្នាក់នៅហ្នឹង ។ ហើយជំនាន់ហ្នឹងយប់ឡើងយួនខាងត្បូងទម្លាក់ភ្លើងតាមដើមឈើ ។

ដានី: ធ្លាប់ជួបអ៊ំនៅខាងជុំគិរី គាត់ថាកាលជំនាន់ហ្នឹងគាត់ដើរធ្វើការជាមួយខាងយៀកកុង ។

ម៉ុត: យៀកកុងហ្នឹងកាលឆ្នាំនេះទេ ឆ្នាំ៧០-៧១យៀកកុងចេញមកហើយជាមួយទ័ពទាហានខ្មែរយើងចូលគ្នា រឹគ្នា ។

ដានី: តាម៉ុក អីដែរ?

ម៉ុត: ហ្នឹងហើយ ។

ដានី: តាស៊ី?

ម៉ុតៈ ហ្នឹងដូរមុខពេញហើយ ព្រៃភ្នំណាក៏មានពួកឃ្មួនដែរ ហ្នឹងហើយមកពីខាងដីរីរមៀល ។

ដានីៈ ឆ្នាំ៧១ ?

ម៉ុតៈ គ្រាន់តែរដ្ឋប្រហារភ្លាមយៀកកុងចូលមកភ្លាម?

ដានីៈ ដួយយើងវ៉ៃជាមួយលន់ នល់ ដែរ?

ម៉ុតៈ វ៉ៃ ។ វ៉ៃខ្លាំងដែរតែវ៉ៃ បានសម្ភារៈអត់ឲ្យខ្មែរយើងទេ ។

ដានីៈ អីចឹង?

ម៉ុតៈ បាទ! តែដល់ឆ្នាំ៧៣ទាស់គ្នា ។

ដានីៈ ទាស់គ្នាយ៉ាងម៉េច?

ម៉ុតៈ ទាស់គ្នារឿងខ្មែរយើងប្រកាន់ថាគណបក្សកម្ពុជាប្រជាធិបតេយ្យហ្នឹង វាបែកចេញពីបក្សឥណ្ឌូចិនហ្នឹងវ៉ៃគ្នា មិនវ៉ៃគ្នាទេគ្រាន់តែធ្វើបាតុកម្មដេញពួកយៀកកុងឲ្យទៅនៅព្រំដែនវិញ ។

ដានីៈ កាលជំនាន់ហ្នឹងពូស្គាល់តាម៉ុក ច្បាស់ហើយ?

ម៉ុតៈ ខ្ញុំអត់ដែលឃើញទេ ទើបមកឃើញកាលផ្ដាច់ខ្លួន មុនផ្ដាច់ខ្លួនចេញមកបញ្ហាឲ្យខាងលោកសង្ឃពណ៌លឿងវ៉ៃជាមួយអ្នកផ្ដាច់ខ្លួនហ្នឹង វ៉ៃសុទ្ធតែគ្នាឯង បានមកផ្ទះព្រលឹមបាក់ទ័ព តាម៉ុក គាត់រត់ទៅថៃ ។ គាត់រត់បានប៉ុន្មានថ្ងៃលឺថាតាប៉ុល ពត សម្លាប់តាសុន សេនចោល ។

ដានីៈ អីចឹងដល់ពេលឆ្នាំ៧៥លោកពូជាមេភូមិមែន តែគេចាត់តាំងឲ្យដើរដឹកប្រឡាយនៅតាមភ្លឺស្រែ ដឹកនាំប្រជាជន?

ម៉ុតៈ ដែលពូៗហ្នឹង ក្មេងៗជាមួយគ្នា គេចាត់តាំងសកលទេ តែភូមិខ្ញុំមានប៉ុន្មាន ថា២០នាក់ ដល់ទៅជាមួយភូមិគេមាន២០-៣០នាក់បូករួមគ្នាគេមានមេកងធំគេមួយនៅចាំ ។

ដានីៈ អីចឹងពូក្រុមជាមួយតាញ៉ោនដែរ ឬអត់ទេ?

ម៉ុតៈ អត់ទេ តាញ៉ោន មិនដែលនៅនេះទេ តាញ៉ោន គេសម្រាប់ចៅហ្វាយស្រុកគេមិនដែលចុះទេ ។

ដានីៈ ដល់បែកឆ្នាំ៧៥ហើយ គាត់នៅតែចៅហ្វាយស្រុកអីចឹង?

ម៉ុតៈ ចៅហ្វាយស្រុកដែរ ។

ដានីៈ ក្រុមតាញ៉ោន មានគ្នាប៉ុន្មាននាក់ធ្វើចៅហ្វាយស្រុក?

ម៉ុតៈ តាញ៉ោន, បងជឿន គេសម្លាប់គាត់ចោលឆ្នាំ៧៥ ។

ដានីៈ សោម ជឿន បងប្អូនតាជន?

ម៉ុតៈ ហ្នឹងហើយ បងប្អូនតាជន ។

ដានីៈ សោម ជឿន, សោម ជន, សោម ដាង?

មុ៉តៈ ហ្នឹងហើយ បងជឿន ហ្នឹងស្លូតណាស់ខ្ញុំស្រឡាញ់គាត់ណាស់ ចុះគាត់សាស្ត្រាចារ្យពីដើម ជួបខ្ញុំដែរ ។ ខ្ញុំមក៧៦គាត់នៅ តែគាត់ជូនខ្ញុំមកឡើងរទេះភ្លើង គេទើបតែវៃចោលក្រោយឆ្នាំ៧៦ ។

ដានីៈ អីចឹងលោកពូយា៉ងម៉េច អាចរៀបរាប់ឆ្នាំ៧៦ ម៉េចបានគេផ្លាស់មកពីខាងអន្លុងវែងមកខាងពាយ័ព្យ?

មុ៉តៈ ខ្ញុំមិនដឹងដែរ ប្អូនខ្ញុំជីដូនមួយនេះគេធ្វើមេឃុំ គេហៅខ្ញុំឲ្យមកដែរ កាលហ្នឹងអត់ចង់មកទេ ម៉ែឪខ្ញុំយំ គេថាអង្គការគេឲ្យមកនៅពាយ័ព្យហ្នឹងគឺសំបូរទឹកដី សំបូរស្រូវច្រើន ឲ្យមកជួយបង្កបង្កើនផលនៅខាងពាយ័ព្យនេះ ព្រោះអីកម្មាភិបាលពាយ័ព្យនេះគ្នាអ្នកមិនសូវបទពិសោធន៍ដឹកនាំ ហើយខ្ញុំមកតាមគេ ។

ដានីៈ កាលហ្នឹងដោយសារប្អូនលោកពូគាត់ធ្វើមេឃុំអ្នកចាត់ឲ្យមក គាត់ឈ្មោះអី?

មុ៉តៈ ខាត់ ។

ដានីៈ ប្អូនជីដូនមួយ?

មុ៉តៈ ប្អូនជីដូនមួយ ។

ដានីៈ ឈ្មោះខាត់?

មុ៉តៈ ហ្នឹងប្អូនថ្លៃ ហើយប្អូនស្រីឈ្មោះសៅ សារីយ៍ ឥឡូវគាត់ធ្វើប្រធានពេទ្យនៅមា៉ឡៃ ។

ដានីៈ ប្រធានពេទ្យស្រុកមា៉ឡៃ?

មុ៉តៈ បាទ! ប្រធានពេទ្យបង្អែក គាត់ខាងពេទ្យឆ្មប ។

ដានីៈ ហើយប្តីគាត់ឈ្មោះខាត់?

មុ៉តៈ ខាត់ តែឥឡូវធ្វើប៉ូលីសនៅឃុំបឹងបេង ស្រុកមា៉ឡៃ ។

ដានីៈ កាលហ្នឹងគាត់ធ្វើមេឃុំអី?

មុ៉តៈ គាត់ពីដើម?

ដានីៈ កាលគាត់នៅកាន់អន្លុងវែង?

មុ៉តៈ ឃុំសំឡាញ តែទើបតែរៀបការបានប៉ុន្មានខែគេឲ្យទៅទៀត ។

ដានីៈ លោកពូមានប្រសាសន៍ថាមក៧៦ ខែប៉ុន្មានទៅដែលមកពីអន្លុងវែង?

មុ៉តៈ មកដូចជាខែប្រាំង ។

ដានីៈ ៧៦ឬ៧៧?

មុ៉តៈ ៧៦ ដូចខែចូលឆ្នាំអីចឹង ខែ៤ មកដល់នេះគេប្រមូលផលអស់ ដឹកស្រូវពេញឡាន ។

ដានីៈ កាលហ្នឹងមកគ្នាច្រើនទេ?

មុំតៈ	មកមនុស្សរាប់ពាន់អ្នក ។ មួយការ៉ុងជិះគ្នា ហើយ៧០ការ៉ុង ។ មនុស្សមកមិនមែនតែប្រជាជនទេ កងទ័ពក៏មានមកខ្លះ ខាងរោងចក្រក៏មានមកខ្លះ មកគ្រប់មុខ មកបែកគ្នានៅ ខ្លះចុះនៅថ្មគោល ខ្លះចុះនៅពោធិ៍សាត់ ហើយខ្ញុំមកចុះនៅស្វាយស៊ីសុផុន ។

ដានីៈ	មកពីស្រុកអន្លង់វែងតែមួយ ឬមានមកពីស្រុកផ្សេងៗទៀត?

មុំតៈ	តំបន់១៣ហ្នឹងមកគ្រប់ស្រុក ។

ដានីៈ	តំបន់១៣ហ្នឹងមកគ្រប់ស្រុក?

មុំតៈ	បាទ! តែមួយស្រុក មួយឃុំគេយក២-៣នាក់ ៤នាក់ ១០នាក់ គេជ្រើសរើសឲ្យមក ។

ដានីៈ	អីចឹងពេលមកជួបជុំគ្នារាប់ពាន់នាក់?

មុំតៈ	បាទ! រាប់ពាន់នាក់ ។

ដានីៈ	ហើយពីណាអ្នកដឹកនាំរាប់ពាន់នាក់មកហ្នឹង?

មុំតៈ	យាយថែម ។

ដានីៈ	យាយថែម គាត់អ្នកដឹកនាំមក?

មុំតៈ	យាយថែម ហើយនិងគម្មាភិបាលស្រុកគេផ្សេងទៀត ដូចថាចុះនៅថ្មគោលគេយកស្រុកត្រាំកក់ដាច់ដោយឡែកទៅ ។

ដានីៈ	ថ្មគោលពីណាគេអ្នកដឹកនាំ?

មុំតៈ	អត់ស្គាល់ ខ្ញុំអត់ស្គាល់ទេ អត់សួរដឹង គេឲ្យមកចេះតែមកនឹងគេ ។

ដានីៈ	ដល់ពេលយាយថែមគាត់ដឹកនាំមក តាញ៉ែន គាត់មកជាមួយដែលអត់?

មុំតៈ	មក ។

ដានីៈ	មកចុះនៅ?

មុំតៈ	ស្រុកសេរីសោភ័ណ្ឌ នៅផ្សារ មកដល់តាញ៉ែន គាត់កាន់នៅគណៈស្រុកសេរីសោភ័ណ្ឌ ។

ដានីៈ	ពេលដែលលោកពូចេញមកពីអន្លង់វែងប៉ុន្មានថ្ងៃទៅបានមកដល់សេរីសោភ័ណ្ឌ?

មុំតៈ	ខ្ញុំដេកនៅតាកែវ២យប់បានដល់ ។

ដានីៈ	ដេកនៅតាកែវ១យប់?

មុំតៈ	ដេកនៅតាកែវ២យប់ បានចេញមកពីភ្នំពេញហ្នឹងមក នៅតាកែវ១យប់ បានឡើងរថភ្លើងមករហូតមកដល់ថ្មគោលម៉ោង៧យប់ កាលហ្នឹងផ្លូវរទេះភ្លើងយើងដាច់ ដឹកបានត្រឹមហ្នឹងបានឡានគេជូនទៅដាក់នៅស្វាយស៊ីសុផុន ។

ដានីៈ	បានឡានគេដឹកមកស្វាយស៊ីសុផុន?

មុំតៈ	បាទ!

ដានី: មកដេកនៅតាកែវបានជួបតាម៉ុក ដែលអត់?

ម៉ុត: ខ្ញុំមហាជនអត់ជួបទេ គេកម្មាភិបាលថ្នាក់ឃុំគេហៅទៅប្រជុំនៅ ។

ដានី: ផ្ទះរបស់គាត់?

ម៉ុត: ប្រជុំនៅទីក្រុងនោះ ហើយខ្ញុំដេកនៅវត្តសីងជិតវ៉ារទេះភ្លើងហ្នឹង មិនដែលជួបទេ ។

ដានី: ដល់ពេលចេញពីតាកែវមកដេកនៅភ្នំពេញមួយយប់ទៀតអត់ទេ?

ម៉ុត: នៅភ្នំពេញអត់ដេកទេមករហូត ឈប់សំរាកមួយភ្លែត អ្ហ៎ូ! ឈប់ដេកនៅភ្នំពេញមួយយប់ ។

ដានី: ដេកនៅកន្លែងណា?

ម៉ុត: ដេកនៅប្រាំងចំរេះ កន្លែងផ្ទះចាមច្រើនគេឲ្យដេកហ្នឹង ។

ដានី: ដេកនៅហ្នឹងដេកធ្វើអី យើងដេកសំរាក ឬក៏ប្រជុំអីដែរ?

ម៉ុត: ហ្នឹងគេដេកឲ្យកម្មាភិបាលគេធំៗគេទៅជួបជាមួយតាប៉ុល ពត គេទៅប្រជុំ យុវជន-យុវកក គេហើយខ្ញុំមហាជនអត់ស្គាល់ ដេកហ្នឹងមួយយប់ដល់ស្អែកឡើងពេលព្រឹកគេដឹកអ្នកទៅទាំងអស់ហ្នឹង ខ្ញុំវិញកូនចៅ គេដឹកឡានដើរលេងជុំវិញភ្នំពេញហ្នឹង គេឲ្យចូលមើលកុន ។

ដានី: លោកពូមកទាំងកូន ទាំងចៅ ទាំងប្រពន្ធទាំងអស់?

ម៉ុត: ខ្ញុំកូន២ តូចៗ ។

ដានី: គេដឹកឲ្យមើលភ្នំពេញយ៉ាងម៉េចដែរកាលជំនាន់នោះ?

ម៉ុត: មើលអីវាលវែសអត់មានមនុស្សផង ។

ដានី: អត់មានមនុស្សទេ?

ម៉ុត: អត់ មានតែកម្មករតាមរោងចក្រ ស្ងាត់ឈឹង ស្រងេះស្រងោចឃើញស្លាកឈីហោរគេដាក់នៅហ្នឹង ផ្ទះខ្លះនៅរូសជញ្ជាំង ដល់កន្លែងណាមានកម្មករ មានកងទ័ពគេធ្វើការនៅម្តុំរោងចក្រអី ខ្លះដាំដំណាំកងទ័ព បើថាប្រជាជនគ្មានទេស្ងាត់ឈឹងតែម្តង ស្ងាត់សូន្យ ។ ហើយតាមសួនច្បារយើងពីដើមដាំផ្កា គេឆាយចោលអស់ ដាំបន្លែ ដាំស្ពៃ ដាំដូង មានល្អអីដូចពីដើម ។

ដានី: តាមផ្លូវអត់មានមនុស្សទេ?

ម៉ុត: អត់មានទេ ។

ដានី: ចុះកម្មករ កងទ័ពអីមានឃើញនៅតាមផ្លូវដែលអត់?

ម៉ុត: តាមផ្លូវមានឃើញតែកងគេធ្វើការ ធ្វើស្រែ គេមានមួយកងគេ ។

ដានី: នៅភ្នំពេញមានធ្វើស្រែដែរ?

មុំតៈ នៅភ្នំពេញធ្វើ នៅជុំវិញភ្នំពេញធ្វើតាំ ដល់ជិះរទេះភ្លើងពីភ្នំពេញរហូតដល់បាត់ដំបងអត់មានឃើញប្រជាជន។

ដានីៈ លោកពូថាគេឲ្យទៅមើលកុន មើលកុននៅកន្លែងណា?

មុំតៈ កុនរោងកុន អត់ស្គាល់ទេ រោងកុនហ្នឹងធំដែរ ចូលទៅអាកូនខ្ញុំតូចៗគេសុទ្ធតែកញ្ចក់ចូលទៅដើរបុកកញ្ចក់ស្រែកពេញហ្នឹង។

ដានីៈ បុកកញ្ចក់?

មុំតៈ បាទ!

ដានីៈ ហើយទៅមើលកុនរឿងអី?

មុំតៈ មានរឿងអី មានតែរឿងហៅថា គេលេងតំបន់រំដោះ គេបញ្ចាំងតែរឿងវៀតណា។

ដានីៈ កងទ័ពបដិវត្តន៍?

មុំតៈ បដិវត្តន៍ គេយកកុនចិនមកបញ្ចាំងរឿងបដិវត្តន៍ចិន ប្រធានម៉ៅ កងវិទ្ធីចាយ ដាំស្រូវលើភ្នំ។

ដានីៈ ហើយគេបកប្រែជាភាសាខ្មែរ?

មុំតៈ បាទ!

ដានីៈ ដល់ពេលចេញមកពីភ្នំពេញ?

មុំតៈ ចេញពីរោងកុនមកកន្លែងស្នាក់នៅ ព្រលឹមឡើងគេដឹកមកដាក់រទេះភ្លើងឡើងមករហូត។

ដានីៈ ឡើងពីភ្នំពេញមកដល់ចុះតាមដំណាក់ទៅ អ្នកចុះនៅពោធិ៍សាត់?

មុំតៈ អ្នកចុះនៅពោធិ៍សាត់ចុះទៅ អ្នកចុះថ្មគោលចុះទៅ។

ដានីៈ អីចឹងរទេះភ្លើងហ្នឹងចាប់ផ្តើម កម្មាភិបាលចាប់ចុះពីត្រឹមពោធិ៍សាត់មក?

មុំតៈ បាទ! ពោធិ៍សាត់។

ដានីៈ ចុះពោធិ៍សាត់ច្រើនអត់?

មុំតៈ ខ្ញុំអត់មើលទេ ការ៉ុងគ្នាពេញ។

ដានីៈ ចុះពោធិ៍សាត់ហើយចុះណាទៀត?

មុំតៈ ចុះនៅពោធិ៍សាត់ខ្លះ ថ្មគោលខ្លះ បានមកដល់សេរីសោភ័ណ្ឌហ្នឹង ហ្នឹងគេដាក់ម្តុំអីចឹង អង្គការគេចែក អ្នកណាទៅនៅភូមិណាៗ តាមស្រុក អ្នកខ្លះដឹកមកដាក់នៅព្រះនេត្រព្រះ ខ្លះដឹកដាក់នៅភ្នំស្រុក តាមតំបន់។

ដានីៈ អីចឹងមកដល់សេរីសោភ័ណ្ឌបើសរុបទៅប៉ុន្មាន មកដល់សេរីសោភ័ណ្ឌ?

មុំតៈ សេរីសោភ័ណ្ឌប្រហែលមួយអាទិត្យចែកចេញអស់។

ដានីៈ ប៉ុន្តែប៉ុន្មាននាក់ទៅ?

ម៉ុតៈ ប្រហែលខ្ទង់១ពាន់ជាងនាក់ ។

ដានីៈ ១ពាន់នាក់ហ្នឹង ក្មេងៗ ចាស់ៗ ឬក៏ចំរុះ?

ម៉ុតៈ មានកងទ័ព មានពួកខាងសហករណ៍គេហ្នឹង ។

ដានីៈ មានកងទ័ពគេដែល កងទ័ពពីណាគេប្រធាន? អ្នកដឹកនាំ?

ម៉ុតៈ អត់ស្គាល់ អត់សូវស្គាល់គេ ។

ដានីៈ អីចឹងមកប្រហែល១ពាន់នាក់ហ្នឹង មកស្នាក់នៅសេរីសោភ័ណ្ឌប្រហែល១អាទិត្យ បានគេបែងចែក?

ម៉ុតៈ បែងចែក ១អាទិត្យគេដឹកចេញតាំងពីដេកនៅ២-៣យប់មុន គេដឹកចេញទំរាំអស់ឡាន២ដឹក

ដានីៈ ពូចាំទេពីណាគេខាងណាខ្លះ?

ម៉ុតៈ ខ្លះទៅភ្នំស្រុក ។

ដានីៈ ភ្នំស្រុកពីណាគេទៅខ្លះ?

ម៉ុតៈ ហ្នឹងតំបន់៣, តំបន់៥ ។ ភ្នំស្រុកអត់សូវស្គាល់ទេ ច្រើនតែមកពីឃុំឆ្ងាយៗពីគ្នា បើឃុំខ្ញុំមកគ្នាប៉ុន្មាននាក់ស្គាល់ ឃុំខ្ញុំមានតែដាក់នៅម្តុំបុស្សស្បូវ ហើយខ្ញុំនៅឃុំស្មៀត បើបងខ្លះនៅខាងសំរោង ២-៣គ្រួសារ បែកគ្នា ។

ដានីៈ លោកពូមកនៅខាងបុស្សស្បូវ?

ម៉ុតៈ អត់ទេខាងស្មៀត ។

ដានីៈ ខាងស្មៀត?

ម៉ុតៈ ខាងស្មៀត សន្កាត់ស្វាយ ។

ដានីៈ កាលហ្នឹងលោកពូមកដល់ឃុំស្មៀត មកជាកាន់ខាងឃុំវិញ?

ម៉ុតៈ ខ្ញុំនៅមេភូមិដដែល ភូមិមួយអាយូសមិនដែលបានធ្វើអីទេ ។

ដានីៈ ភូមិអីគេ?

ម៉ុតៈ ភូមិថ្មី ។

ដានីៈ មកកាន់មេភូមិថ្មីវិញ?

ម៉ុតៈ បាទ!

ដានីៈ ចុះឃុំស្មៀតពីណាគេកាន់?

ម៉ុតៈ ឃុំស្មៀតហ្នឹងប្អូនជីដូនមួយខ្ញុំ ។

ដានីៈ ប្អូនជីដូនមួយឈ្មោះខាត់ហ្នឹង?

ម៉ុតៈ បាទ!

ដានី៖ ហើយចុះខាងឃុំបុស្សស្បូវ?

ម៉ុត៖ គាឪ តែគាត់ស្លាប់បាត់ ។

ដានី៖ មានប៉ុន្មានឃុំនៅស្រុកសេរីសោភណ្ឌ?

ម៉ុត៖ សេរីសោភ័ណ្ឌ, ឃុំស្មៀត, ឃុំបុស្សស្បូវ, ឃុំសឹង, ឃុំចង្ហា ។

ដានី៖ ចាំមើលមុនដំបូងឃុំស្មៀត?

ម៉ុត៖ ខ្មៀត ។

ដានី៖ ខ្មៀត, បុស្សស្បូវ, សឹង, សង្ហា, សំរោង ។

ម៉ុត៖ សំរោង, ម្ភាក់ ជំនាន់ហ្នឹងដូចមានប៉ុណ្ណឹង ។

ដានី៖ ទឹកថ្លាអត់មានទេ?

ម៉ុត៖ អត់ទេ ឃុំទឹកថ្លាមួយទៀត ។

ដានី៖ ឃុំខ្មៀតនេះប្អូនជីដូនមួយពូកាន់ ឈ្មោះខាត់ អ៊ីចឹង គាត់កាន់ទាំងពីរនាក់ប្ដីប្រពន្ធ ចុះបុស្សស្បូវ?

ម៉ុត៖ ឪ ស្លាប់បាត់ ។

ដានី៖ ចុះសឹង?

ម៉ុត៖ សឹង ខ្ញុំអត់ដឹង ឈ្មោះស្អីទេស្លាប់ដែរ ឈ្មោះអៀង ។

ដានី៖ ចុះសង្ហា?

ម៉ុត៖ សង្ហា តាយ៉ង ។

ដានី៖ គាត់នៅណាដែរ?

ម៉ុត៖ អាចារ្យវត្ត ។

ដានី៖ អាចារ្យវត្តនៅណា?

ម៉ុត៖ វត្តអូរជុំ ។

ដានី៖ អ៊ូ! អូរជុំគីឡូ១៣?

ម៉ុត៖ បាទ!

ដានី៖ ខ្ញុំទៅធ្វើនៅហ្នឹង នៅអូរជុំដែរតែអត់ដឹង ។

ម៉ុត៖ តាមួយខ្មៅ ។

ដានី៖ ចុះសំរោង?

ម៉ុត៖ សំរោងដូចជាជឿន នៅគីឡូ១៣ ។

ដានី៖ ស្គាល់គាត់ ។ ម្ភាក់?

ម៉ុត: ម្ដាក់ ផាត ។

ដានី: នៅជិតនេះគាត់ទើបតែស្លាប់ ។

ម៉ុត: ផាត ខ្វាក់នៅវត្ត ។

ដានី: បាទ! ជិតបារាំងធ្លាក់ ។

ម៉ុត: បាទ ។ ទឹកថ្លាមិនដឹងពីណាគេ ។

ដានី: ទឹកថ្លាមិនមែនប្រពន្ធគាត់ទេ?

ម៉ុត: ទឹកថ្លាមិនមែនទេ តែផាត ចូលដល់មុនដឹបូងនៅទឹកថ្លាដល់ហើយបានផ្លាស់ទៅនៅម្ដាក់ ។

ដានី: ហើយខាងគណៈស្រុកមានតាញ៉ែន ម្នាក់ទេ មានពីណាអនុគាត់?

ម៉ុត: មានតែគាត់មួយ តែមានគេចាស់នៅនេះខ្លះកាន់ជាមួយគ្នា ។

ដានី: ពីណាគេ?

ម៉ុត: អត់ស្គាល់ទេ ។

ដានី: ចុះខាងឃុំគាត់អត់មានទៅជាទទួលស្រុកណាអត់ទេ?

ម៉ុត: អត់ ។

ដានី: តាញ៉ែន គាត់កាន់រហូត ឬមានការផ្លាស់ប្ដូរដែរ?

ម៉ុត: តាញ៉ែន គាត់នៅហ្នឹងបានប៉ុន្មានគាត់ផ្លាស់ទៅភ្នំស្រុកវិញបាន៣ឆ្នាំដល់ឆ្នាំ៧៩ ។

ដានី: ផ្លាស់ទៅភ្នំស្រុកពីណាជំនួសគាត់ ពេលគាត់ផ្លាស់ទៅភ្នំស្រុក?

ម៉ុត: តាសឹម នៅចក្រី ។

ដានី: តាសឹម មកជំនួស?

ម៉ុត: តាសឹម, តាប៉ូ, តាឈន ។

ដានី: តាប៉ូ?

ម៉ុត: តាប៉ូ ស្លាប់បាត់ ។

ដានី: តាប៉ូ, តាឈន?

ម៉ុត: ស្លាប់ជាមួយបងសារឿន ។

ដានី: តាសឹម គាត់នៅចក្រីឥឡូវ?

ម៉ុត: បាទ!

ដានី: ចក្រី នៅក្នុងឃុំអីគេ?

ម៉ុត: នៅក្នុងឃុំបារាំងធ្លាក់ កាលមុននៅឃុំចក្រីតែឥឡូវកាត់ ។

ដានី៖ អីចឹងពេលតាញ៉ែន គាត់ផ្លាស់ទៅភ្នំស្រុក តាសឹម ឡើងមកគណៈស្រុកជំនួស ចុះតាសឹម កាលមុនគាត់កាន់អីទៅ?

ម៉ុត៖ តាសឹម គាត់នៅស្រុក ទើបតែផ្លាស់មកជំនាន់ឆ្នាំ៧៧ ឆ្នាំ៧៧-៧៨ ។

ដានី៖ គាត់មកក្រោយគេ?

ម៉ុត៖ មកក្រោយ គណៈតំបន់ក៏ផ្លាស់ កាលមុនបងហេង រិន ។

ដានី៖ បងហេង រិន?

ម៉ុត៖ បាទ!

ដានី៖ គណៈតំបន់៥ ។

ម៉ុត៖ បងជា ភួងភារម្យ ។

ដានី៖ បងពីណាគេ?

ម៉ុត៖ បាទ!

ដានី៖ គណៈតំបន់៥ឈ្មោះតាហេង រិន ត្រូវជាបងប្រុស ជា ភួងភារម្យ ។

ម៉ុត៖ មេឃុំម្នាក់ បងមែន សែប អចិន្ត្រៃយ៍ឃុំជាមួយគ្នា ។

ដានី៖ គាត់ឈ្មោះអី?

ម៉ុត៖ មែន សែប ។

ដានី៖ គាត់មេឃុំភ្នំព្រឹកឥឡូវ ។ តាសឹម ហ្នឹងគាត់មកក្រោយទេ?

ម៉ុត៖ ក្រោយ មកឆ្នាំ៧៨ ។

ដានី៖ អីចឹងតាញ៉ែន គាត់ផ្លាស់ទៅឆ្នាំ៧៨ទេ?

ម៉ុត៖ បាទ!

ដានី៖ ហើយតាសឹម ប្រពន្ធគាត់ឈ្មោះអី?

ម៉ុត៖ រីម ។

ដានី៖ គាត់ធ្វើការងារដែរ?

ម៉ុត៖ អត់ទេគាត់មេផ្ទះ គាត់អាយុប៉ែតជាងវង្វេងវង្វាំង ។

ដានី៖ តាសឹម គាត់នៅមាំ?

ម៉ុត៖ នៅមាំ តែអាយុគាត់ច្រើន ។

ដានី៖ គាត់នៅបារាំងធ្លាក់មានធ្វើអាចារ្យដែលអត់?

ម៉ុត៖ ធ្វើអាចារ្យគណៈកម្មាធិការដែរ តែឥឡូវចាស់គាត់ឈប់ ។

ដានី៖ ចុះគណៈតំបន់៥ ហេង រិន គាត់ទៅណាទៅ?

មុំតៈ	គេចាប់គាត់ដាក់គុកយកមកភ្នំពេញ ។

ដានី:	ចាប់ឆ្នាំណាទៅចាប់យកមកដាក់?

មុំតៈ	៧៨ ។

ដានី:	៧៨ប្រហែលជាខែប៉ុន្មានគេចាប់គាត់?

មុំតៈ	មិនដឹងខែប៉ុន្មាន ។

ដានី:	ដល់ពេលគាត់ទៅតាចាយ មក?

មុំតៈ	តាចាយ ។

ដានី:	តាចាយ មកជំនួស?

មុំតៈ	តាចាយ មកដល់៧៩ តាចាយ មកកាន់កាប់បានមួយឆ្នាំ ។

ដានី:	តាចាយ គាត់មកពីណា?

មុំតៈ	គាត់មកពីកំពត មកពីតំបន់តាកែវ ។

ដានី:	តាចាយ មកកាន់ជំនួស?

មុំតៈ	តាចាយ កាន់ជាមួយ យាយថែម ។

ដានី:	គាត់កាន់គ្នា២នាក់?

មុំតៈ	មិនដឹងពីណាទៀតទេអត់សូវស្គាល់ទេ គាត់ធ្វើគណៈតំបន់គាត់ហៅប្រជុំញឹកណាស់ ។

ដានី:	តែគណៈតំបន់ដំបូងតារិននេះគាត់អត់ ហេង រិន នេះគណៈតំបន់ បន្ទាប់ៗគាត់មកមានពីណាខ្លះ?

មុំតៈ	កាលហ្នឹងគាត់ធ្វើការចូលជាមួយដាល ។

ដានី:	ហេង រិន, ដាល ពីណាទៀត?

មុំតៈ	យាយថែម ។ ស្អីគេខ្ទាក់ភ្នែកម្នាងហ្នឹងចាប់មុនដាល ទៀត ។

ដានី:	ដែលលឺឈ្មោះតាហឹង ដែលអត់?

មុំតៈ	ដែល ។

ដានី:	តែអត់មកទាន់គាត់?

មុំតៈ	អត់ទាន់ ។ តាដាល ហើយបងអីមួយទៀត ។

ដានី:	តាវ៉ាល់?

មុំតៈ	ខ្ញុំតាំងពីកើត៧៥ភ័យរហូត ។

ដានី:	ចុះខាងតំបន់៥ហ្នឹងមានស្រុកសេរីសោភណ្ឌ ។

មុំតៈ	ព្រះនេត្រព្រះ, ភ្នំស្រុក, ថ្មពួក ។

ដានី: ៩ហ្នឹង? មន្ទីរបុរីអត់ទេ?

ម៉ុត: មន្ទីរបុរីខាងតំបន់៣ ។

ដានី: មន្ទីរបុរីខាងតំបន់៣ ព្រះនេត្រព្រះ, ភ្នំស្រុក, ថ្មពួក ខាងស្វាយចេកអត់មានទេ?

ម៉ុត: ស្រុកស្វាយចេក, ថ្មពួកហ្នឹង ។

ដានី: តែ៩អីចឹងជំនាន់ហ្នឹង ។ សេរីសោភ័ណ្ឌដំបូងតាញ៉ែន ព្រះនេត្រព្រះ?

ម៉ុត: អត់ស្គាល់ទេ ។

ដានី: យាយថែម?

ម៉ុត: ព្រះនេត្រព្រះគាត់ក្នុងគណៈកម្មាធិការតំបន់ ។

ដានី: គាត់តំបន់ផង គាត់កាន់ស្រុកផង ។ ចុះខាងភ្នំស្រុក?

ម៉ុត: មិនស្គាល់ទេ ជំនាន់នោះអត់ស្គាល់គេ ។

ដានី: តែក្រោយមកបានតាញ៉ែន គាត់ផ្លាស់ទៅ ។ មកនេះតែតាញ៉ែន ទេ ហើយតាសឹម គាត់មកជំនួស ចុះខាងថ្មពួក?

ម៉ុត: ខាងថ្មពួកមានតារៀម ។

ដានី: តារៀម លក់សាំង?

ម៉ុត: តារៀម គេចាប់ទៅម្ដង ។

ដានី: គេចាប់គាត់ដែរ?

ម៉ុត: គេចាប់ ។

ដានី: គេចាប់ឆ្នាំណា?

ម៉ុត: ចាប់ឆ្នាំ៧៦ ចាប់ទៅ១ឆ្នាំបានឃើញត្រឡប់មកវិញ គាត់កាន់ខាងកងទ័ព ។

ដានី: គាត់កាន់ខាងកងទ័ពហើយបានគាត់មកធ្វើគណៈស្រុកវិញ ។

ម៉ុត: កាន់កងទ័ពគេចោទគាត់ មនុស្សមិនសុទ្ធ ។

ដានី: គេយកមកដាក់តាកែវវិញ?

ម៉ុត: មិនដឹងយកដាក់ឯណា បាត់មួយរយៈ ដឹងតែចាប់មិនដឹងទៅណា ចាប់រួចអស់ច្រើនដែរ ។

ដានី: ហេង រិន ហ្នឹងគាត់ត្រូវបងប្រុសបង្កើតរបស់ ជា ភួងភារម្យ ហ្នឹងបង្កើតតែម្ដង?

ម៉ុត: បាទ!

ដានី: ជា ភួងភារម្យ ហ្នឹងកាលជំនាន់ហ្នឹងគាត់នៅហ្នឹងដែលអត់ទេ?

ម៉ុត: អត់ទេ គាត់នៅកោះកុង គាត់ធ្វើសហករណ៍នៅកោះកុង ។

ដានី: គាត់អត់នៅជាមួយគ្នាទេ ។

ម៉ុតៈ បងប្អូនគាត់ច្រើនណាស់ស្លាប់អស់ហើយ គាត់ទ័ព ៥-៦នាក់នៅសល់តែគាត់ ។

ដានីៈ លោកពូពេលដែលលោកពូមកដល់ឃុំខ្មៀតហ្នឹងធ្វើអីខ្លះទៅ? ការងារ?

ម៉ុតៈ ការងារធ្វើស្រែ ។

ដានីៈ ហើយពេលដែលមកដល់ដំបូងឃើញទិដ្ឋភាពនៅស្រុកគេយ៉ាងម៉េច ខុសពីខាងនៅស្រុកកំណើត?

ម៉ុតៈ ទិដ្ឋភាពដូចថាវាលវាល ហើយខែភ្លៀងទឹកលិច ហើយមកដល់មុនដំបូងដូចសប្បាយឃើញស្រូវបាន ដឹកអស់រលីង ។

ដានីៈ ដឹកទៅណា?

ម៉ុតៈ មិនដឹងដឹកទៅណាអង្គការគេ ដឹកៗឡាន ។

ដានីៈ ធ្វើបានច្រើនដែលអីចឹង?

ម៉ុតៈ ស្រូវរាប់ម៉ឺន រាប់ពាន់តោន តែប្រជាជនអស់ហើយដំរុំមួយ ប្រវែង២០-៣០ម៉ែត្រ កិន ៧-៨នាក់ ហើយឆ្នាំហ្នឹងស្រូវកើត ដឹកអស់រលីង ដឹកអស់ៗដល់អត់អីឲ្យប្រជាជនហូប ដល់ពេលខ្ញុំមកនៅហ្នឹងរងកម្មបណ្ដោយ បានហូបតែខែប្រាំងបានប៉ុន្មានខែ ដល់ខែវស្សាចាប់ផ្ដើមបបរហូប រហូតដល់រត់យួន ថាយួនចូលហ្នឹង ហូបបបររហូត ស្រុកហ្នឹងសំបូរត្រកួន ត្រកួនលិចទឹកត្រឹមៗនេះ ម្ហូបអត់ខ្វះហូបទេ ។

ដានីៈ លោកពូមកពីហ្នឹងមកធ្វើគ្រប់គ្រង មកធ្វើស្រែចំការ បានស្រូវគេយកទៅអស់?

ម៉ុតៈ កាលជំនាន់ហ្នឹងអត់មានទេ កាលហ្នឹងគេដឹកទៅមួយហឹក ដល់ពេលនេះគេលើកមាត៌មួយនេះអង្គការគេអត់ឲ្យធ្វើស្រូវឡើងទឹក ព្រោះអីស្រុកហ្នឹងបានផលតែស្រូវទឹកលិចទេ ទឹកលិចកំពស់៤-៥ម៉ែត្រនោះ ស្រូវឡើងទឹកប្រជាជនធ្វើតាំងពីដូនតាគាត់មក អត់ធ្វើស្រូវឡើងទឹកកន្ទុយវែងអង្ករក្រហមណាអត់ទេ ស្រូវឡើងទឹកគេបាយឆ្ងាញ់ដូចអង្ករយើងស្រូវឆ្ងាញ់កម្មាភិបាល ជាល ហ្នឹងគេអភិវឌ្ឍន៍គេអត់ឲ្យដាំ អត់ឲ្យធ្វើ ស៊ីពូជហ្នឹងអស់ទៅ ។

ដានីៈ អត់ឲ្យដាំ?

ម៉ុតៈ ខ្ញុំមកក្រោយមានពូជណាធ្វើ បើពូជដឹកយកទៅអស់ហើយ ដល់បានឆ្នាំរត់យួនចូលមកហ្នឹងឆ្នាំ៧៨-៧៩បានបង្កបង្កើតរកពូជគេពីក្រៅៗធ្វើបានច្រើន ដល់ពេលស្រូវទុំបានបែករត់ចោលប្រជាជននៅនេះប្រូតយក ស្រូវល្អណាស់ ចុះគេធ្វើពីដើមដែល គោលការណ៍គាត់មកខ្ញុំសួរចុះអុំពីដូនតា គាត់ថាធ្វើតែអីចឹងឯង តាំងពីគាត់កើតមកធ្វើតែស្រូវឡើងទឹក ហើយគេពិសោធន៍ស្ទូងក្បែរថ្នល់ជាតិ ស្ទូងស្រូវស្រាលយើងគ្រាន់តែស្រូវចេញទឹកឡើងប្រើបលិចបាត់អស់រលីង ទឹក៣-៤ម៉ែត្រ ។

ដានី៖ អីចឹងយើងធ្វើស្រូវអត់បាន?

ម៉ុត៖ អត់បាន ។

ដានី៖ អីចឹងហូបបបរទេ?

ម៉ុត៖ ហូបបបរ បបរហ្នឹងមិនចង់បានហូបទៀត ដល់ពេលឆ្នាំខ្ញុំនៅអត់ស្លូវមានទេ បានឃុំបុស្សស្បូវ សំរោង, ម្កាក់, សឹង គេនៅដីលើគេបានជួយ ដល់សុំគេបាន២-៣រយបាយ មួយសហករណ៍ហ្នឹងចន្ទ្រានគ្នា២-៣រយនាក់ បានអង្ករ៣០កំប៉ុង ។

ដានី៖ កាលហ្នឹងប្រជាជនច្រើនអត់?

ម៉ុត៖ ច្រើន ។

ដានី៖ ប្រជាជននៅហ្នឹងច្រើន ឬក៏ប្រជាជនថ្មី?

ម៉ុត៖ ប្រជាជនថ្មីមកពាក់កណ្ដាល ប្រជាជនចោះពាក់កណ្ដាល ខ្លះជម្លៀសមកពីភ្នំពេញ ខ្លះស្រុកកំណើតនៅពោធិ៍សាត់ នៅកំពង់ស្ពឺ សុទ្ធចំរុះ ព្រោះកាលជំនាន់លន់ នល់ ចេះតែដើររកស៊ី ដល់ពេលគេវៃបែកប្រឹបរត់ទៅណារួច អន្តការគេជម្លៀសឲ្យទៅណាទៅហ្នឹង ម៉េចហ៊ានប្រឆាំង ចេះតែមកបែកស្រុក បែកទេស ។

ដានី៖ តាដាល ហ្នឹងគាត់អត់ឲ្យធ្វើស្រែ អាស្រែឡើងទឹក?

ម៉ុត៖ ហ្នឹង ។

ដានី៖ ដាល ពេលដែលលោកពូមកយូរទេដែលគេចាប់ទៅ?

ម៉ុត៖ មកបានមួយឆ្នាំ ។

ដានី៖ បានមួយឆ្នាំគេចាប់ដាលហ្នឹងទៅ?

ម៉ុត៖ បាទ! ចុង៧/៧ ។

ដានី៖ គេចាប់ដាល ហ្នឹងទៅ?

ម៉ុត៖ តារស់ ញឹម, ដាល ហ្នឹងគេចាប់កាលចុង៧/៧ ។

ដានី៖ គេចាប់ដាល ហើយរស់ ញឹម ទៅ នៅសល់តែតាហេង រិន ទេ?

ម៉ុត៖ តាហេង រិន នៅបានតែប៉ុន្មានខែ មានពាក់ព័ន្ធជាមួយតាកង ចាប ភូមិភាគឧត្ដរគេចាប់តាកង ចាប ចាប់គាត់ទៅ ។

ដានី៖ ចាប់តារិនទៅដែរ?

ម៉ុត៖ មានពាក់ព័ន្ធ ។

ដានី៖ កាលហ្នឹងតារិន ហើយលោកពូស្គាល់គ្នាច្បាស់ និយាយគ្នាដែលអត់?

មុំតៈ	មិនស្គាល់គ្នាច្បាស់ទេ គ្រាន់តែជួបធ្វើការងារ គ្រាន់តែនិយាយគ្នាធម្មតា ការងារ គាត់មកធ្វើស្រែ តាហ្នឹងមិនដែលនៅមន្ទីរទេ គាត់ដើរសួរតាមប្រជាជនរហូត ។

ដានីៈ	គាត់ធ្វើស្រែ សួរតាមប្រជាជនដែរ?

មុំតៈ	បាទ! គាត់លុតដីគាត់ខ្លាំងណាស់ គាត់ខ្លាចណាស់ គាត់ធ្វើប៉ុណ្ណឹងហើយនៅតែគាត់ខុសទៀត ប្រជាជនណាក៏គេអាណិតគាត់ដែរ ចុះកាលហ្នឹងនិន្នាការគាត់វាបញ្ហាវិន្តគាត់រៀនថ្នាក់ខ្ពស់ កាលគាត់នៅបួសគាត់រៀន ។

ដានីៈ	គេហៅគាត់មួយទៀត រិន ញ៉ៅ ហ្នឹងមែន?

មុំតៈ	ហ្នឹងហើយ រិន ញ៉ៅ មិនមែនតារិនដៃត្រង់ទេ តារិនដៃត្រង់ ស្លាប់បាត់ហើយ ។

ដានីៈ	គាត់ធ្វើអី តារិនដៃត្រង់?

មុំតៈ	គាត់គណៈតំបន់ដែរ គាត់នៅកន្លែងមន្ទីរ គាត់គណៈតំបន់ដែរ ។

ដានីៈ	គណៈតំបន់ជាមួយយាយថែម?

មុំតៈ	មិនទេ ដូចអ្នកនៅខាងហ្នឹង សៀមរាប ។

ដានីៈ	ដល់ពេលតាជាល គេចាប់ទៅ តារិន ក្រោយមកគេចាប់ទៀតទៅ នៅតែយាយថែម?

មុំតៈ	នៅសល់យាយថែម បានតាចាយ មក ។

ដានីៈ	តាចាយ មក ពីណាធ្វើប្រធាន ពីណាធ្វើអនុ?

មុំតៈ	តាចាយ ប្រធាន ។

ដានីៈ	តាចាយ មកបានយូរទេ?

មុំតៈ	មកបានជិតមួយឆ្នាំដែរ ៧៩ ។

ដានីៈ	ហើយកាលហ្នឹងស្ថានភាពយ៉ាងម៉េចដែរ?

មុំតៈ	ស្ថានភាពលំបាកណាស់ក្នុយជំនាន់ហ្នឹង ក្អែកលលក ដល់ថ្ងៃគេហៅរៀនសូត្រ ។

ដានីៈ	ក្នាឯងដែលមកពីខាងកំពត-តាកែវក៏ក្អែកលលកដែរ?

មុំតៈ	ហ្នឹងហើយ ។

ដានីៈ	កាលមកនេះហ្នឹង តារិន គាត់អត់មកជាមួយទេ?

មុំតៈ	អត់ទេ គាត់មកក្រោយ ។

ដានីៈ	តារិន គាត់មកក្រោយទេ?

មុំតៈ	មកជំនាន់ហ្នឹងកម្មាភិបាលចាស់ ហើយនិងកម្មាភិបាលមកក្រោយអត់ត្រូវគ្នាទេ តាជាលរករឿងរ៉ៃគ្នា ។

ដានីៈ	រករឿងពីណា?

ម៉ុតៈ	រករឿងអ្នកមកក្រោយ មកនៅយាយចែម ទំនាស់គ្នា តារៀម ប្រឆាំងគ្នា។ តារស់ ញឹម គាត់ប្រឆាំងជាមួយតាម៉ុក ហើយពួកដែលទៅហ្នឹងសុទ្ធតែកូនចៅតាម៉ុក ប្រឆាំងគ្នាសុទ្ធតែជីដងដាក់គ្នា រកវ៉ៃគ្នា សុទ្ធតែកាន់អាវុធរៀងខ្លួន ហើយខ្ញុំអត់ដឹងអីទេ បានគេប្រាប់ គេរកវ៉ៃគ្នានៅវត្តស្វាយហ្នឹង ខ្ញុំពីរនាក់បងប្អូនប្រជាជននៅមូលដ្ឋានហ្នឹង ដើររកសុំឫស្សីធ្វើបំពង់ទឹកត្នោត បានឪ្យបប្រាប់ឯងកុំទៅគេរកវ៉ៃគ្នា បាញ់គ្នាងាប់ឥឡូវ គេរកតែពួកនិរតី ខ្ញុំភ័យរត់អត់ឈប់

ដានីៈ	យាយចែម, តារៀម គាត់អត់ត្រូវជាមួយជាល ហ្នឹងទេ?

ម៉ុតៈ	អត់សូវត្រូវគ្នាទេជំនាន់ហ្នឹង។

ដានីៈ	ពូដែលឃើញគាត់ឈ្លោះគ្នា ប្រកែកគ្នាដែលអត់?

ម៉ុតៈ	អត់ដែលឃើញឈ្លោះ គេឈ្លោះគ្នាតែក្នុងអង្គប្រជុំ ផ្ទៃក្នុងអ្នកធំជំនាន់ហ្នឹង និយាយត្រូវគ្នាតែផែនការអនុវត្តន៍ខុសគ្នា ផ្ទៃក្នុងគេលំបាកណាស់។

ដានីៈ	លោកពូដឹងថាម៉េចបានគេឈ្លោះគ្នា?

ម៉ុតៈ	គាត់ឈ្លោះគ្នា ចោទគ្នាសុទ្ធតែនិរតីធ្វើការមិនកើត ខាងពាយ័ព្យចោទនិរតីចេះចុះ និរតីចោទពាយ័ព្យថាក្បត់ ចោទគ្នាទៅវិញទៅមក។

ដានីៈ	រួចរកវ៉ៃគ្នាតែម្តង?

ម៉ុតៈ	វ៉ៃគ្នា។

ដានីៈ	រកវ៉ៃគ្នានៅកន្លែងណា?

ម៉ុតៈ	នៅស្វាយស៊ីសុផុនកន្លែងណាខ្ញុំអត់ដឹង នៅវត្តស្វាយ ជំនាន់ហ្នឹងគ្រាន់តែកម្មករពេងចក្រក៏អត់ត្រូវគ្នាដែរ បក្សពួកនិយម។

ដានីៈ	ហើយបើតាមពូចាំកាលនោះតារៀម យាយចែម ប្រុងវ៉ៃជាមួយជាល?

ម៉ុតៈ	គាត់ទំនាស់គ្នាពាក្យសំដីផ្ទៃក្នុងគេ តែចំពោះកងទ័ពៗកាន់មេម៉េចទេ។

ដានីៈ	គេមានទ័ពរៀងខ្លួន?

ម៉ុតៈ	ទ័ពរៀងខ្លួន គ្រាន់តែសេនាជនយាមផ្លូវឃើញពួកនិរតីមកអត់ឲ្យទៅទេ ប្រកាន់គ្នាអីចឹង។

ដានីៈ	តារៀម កាលនេះគាត់ធ្វើធំដែរ?

ម៉ុតៈ	តារៀម គាត់កាន់កងទ័ពស្រុក។

ដានីៈ	កាន់កងទ័ពស្រុកណា?

ម៉ុតៈ	ស្រុកសេរីសោភ័ណ្ឌ កងទ័ពតំបន់។

ដានីៈ	ចេញពីកងទ័ពតំបន់បានគាត់ទៅធ្វើគណៈស្រុក?

ម៉ុតៈ	កងទ័ពតំបន់គេចាប់គាត់បាត់ទៅ ដល់នេះបានឃើញឲ្យមកធ្វើចៅហ្វាយស្រុកថ្មពួក។

ដានីៈ ចាប់គាត់ទៅបានឡូមកធ្វើចៅហ្វាយស្រុកថ្មពួក?

ម៉ុតៈ គេចាប់ទៅ គេឆ្លើយដាក់ដល់រកភស្តុតាងមិនឃើញ ។

ដានីៈ លោកពូឃើញតែចាប់ចង១ កន្លែងនៅខាងស្វាយមានកន្លែងសម្លាប់ មានកន្លែងសន្តិសុខដែរ?

ម៉ុតៈ មាន! កន្លែងភ្នំកងវ៉ា ។

ដានីៈ ភ្នំកងវ៉ា កន្លែងចំការកប្បាស?

ម៉ុតៈ ហ្នឹងហើយ ហ្នឹងកន្លែងមន្ទីរធំហើយ ។

ដានីៈ ហ្នឹងគេហៅមន្ទីរអីគេ?

ម៉ុតៈ ភ្នំកងវ៉ាអីកន្លែងភ្នំពង្រ ។

ដានីៈ ភ្នំស្វាយហ្នឹង?

ម៉ុតៈ ភ្នំស្វាយ ហ្នឹងកន្លែងសាលារៀនចាស់ ខ្ញុំដែលទៅម្តងដែលអត់ហ៊ានមើលគេ គេមិនឲ្យចូលទៅជិតគេ កាលហ្នឹងទៅជីកស្រូវបរកាត់ ហើយឃើញ ។

ដានីៈ ឃើញគេសម្លាប់ដែរ?

ម៉ុតៈ អត់ដែល ។

ដានីៈ អត់ដែលឃើញខ្មោច?

ម៉ុតៈ គេមិនដែលកប់ឲ្យយើងឃើញ គេមិនដែលវ៉ៃចោលឲ្យយើងឃើញទេ ។

ដានីៈ ពេលយប់បានគេវ៉ៃ?

ម៉ុតៈ បាទ!

ដានីៈ ហើយកន្លែងភ្នំស្វាយ ហ្នឹងកន្លែងមន្ទីរសន្តិសុខគេ?

ម៉ុតៈ បាទ!

ដានីៈ មន្ទីរសន្តិសុខរបស់ស្អីគេ? របស់តំបន់ ឬរបស់ស្រុក?

ម៉ុតៈ របស់តំបន់ ។

ដានីៈ មន្ទីរសន្តិសុខហ្នឹងមានតែមួយទេអីចឹង? ហើយចោទគ្នាទៅវិញទៅមក ចាប់ទៅចាប់មក?

ម៉ុតៈ ចាប់ទៅចាប់មកជិនាន់ហ្នឹង ដល់ពេលតាចាយ មកលែងចាប់ហើយ ស្ងប់ស្ងាត់ ចុះសមរភូមិមុខអស់ហើយ ។

ដានីៈ លោកពូដែលទៅប្រជុំជាមួយតាចាយ, យាយចែមអីដែលអត់?

ម៉ុតៈ ទៅយូរៗម្តង គេហៅទៅម្តង ដូចជាផែនការគេហៅមេភូមិ ប្រជុំដាក់ផែនការធ្វើស្រែចំការគេហៅទៅ ។

ដានី៖ ហៅទៅភាគច្រើនប្រជុំរឿងអី?

ម៉ុត៖ ភាគច្រើននិយាយពីរឿង១ហិចតា៣តោនហ្នឹង ។

ដានី៖ ធ្វើម៉េចបាន១ហិចតា៣តោន?

ម៉ុត៖ កំលាំងប្រជាជនឲ្យធ្វើជីអាចម៍ ចេះតែធ្វើទៅ ។

ដានី៖ រួចធ្វើបានអត់ ១ហិចតា៣តោន?

ម៉ុត៖ មិនបាន បើដីគេលើគេធ្វើបាន ដីខ្ញុំក្បាលទឹកធ្វើអីកើត ។

ដានី៖ បើយើងធ្វើអត់បានអីចឹង អត់សំរេចផែនការបានយើងធ្វើម៉េចទៅ?

ម៉ុត៖ សំរេចផែនការមិនបានជួនកាលគេដកចេញ ។

ដានី៖ កាលជំនាន់ហ្នឹងគ្រួសាររបស់លោកពូមករស់នៅក្នុងភូមិជុំគ្នានៅខាងខ្មៀតហ្នឹងមកជុំគ្នា?

ម៉ុត៖ មេភូមិអត់បែកគ្នាទេ ភូមិនៅជាមួយគ្នា ដល់បែងចែកផែនការអង្គការគេថាគ្រួសារមេភូមិនៅនេះឲ្យកាន់ខាងកងជី គ្រួសារខ្ញុំកាលនៅស្រុកមុនមកនេះ មិនដែលជួបគ្នាទេគេឲ្យកាន់ខាងកងជីដឹកជីជំបូកមិនដែលនៅផ្ទះទេ ។

ដានី៖ អីចឹងយាយចែម កាលហ្នឹងគាត់ទស្សរាហ៍នៅស្វាយដែរ?

ម៉ុត៖ នៅស្វាយផង នៅព្រះនេត្រព្រះផង គាត់កាន់ស្រុក ។

ដានី៖ គាត់ជិះអីទៅ? គាត់ទៅមក?

ម៉ុត៖ ជិះស៊ុទ្ធតែឡាន ឡានjeep គណៈតំបន់ស៊ុទ្ធឡាន គណៈស្រុកម៉ូតូ ។

ដានី៖ យាយចែមគាត់ប្រជុំ គាត់និយាយល្អដែរ?

ម៉ុត៖ និយាយល្អ គេនិយាយម៉ឺងម៉ាត់ គេនិយាយតាមឯកសារ ជំនាន់ហ្នឹងមានសៀវភៅទង់បក្សគេនិយាយមានអីមានតែបញ្ហាខ្មាំង សក្តិភូមិនាយទុនហ្នឹងឯង បក្សពលករខ្មែរ ដឹកនាំ ។

ដានី៖ ដូចជាតាញ៉ែន គាត់នាំជាគណៈស្រុកគាត់ប្រជុំគាត់និយាយយ៉ាងម៉េចដែរ?

ម៉ុត៖ ប្រជុំផែនការ កាលហ្នឹងនិយាយរឿងបោសសម្អាតខ្មាំង ។

ដានី៖ និយាយរឿងបោសសម្អាតខ្មាំង?

ម៉ុត៖ អឺ! ខ្មាំង ។

ដានី៖ គាត់និយាយមើលទៅសមរម្យពូកែនិយាយដែលអត់?

ម៉ុត៖ និយាយគ្នាឯង និយាយជាមួយកូនចៅ និយាយខ្លីៗ ។

ដានី៖ ចឹងនិយាយខ្លីៗទេ?

ម៉ុត៖ បើប្រជុំសាមញ្ញនិយាយវែង ។

ដានី៖ ចឹងលោកនៅហ្នឹងរហូតដល់យួនចូលឆ្នាំ៧៩?

មុំតៈ បាទ! ដល់៧៩ខ្ញុំរត់ ចេញពីទាហានទៅដល់តាប៉ែន រត់ចឹងទៅបានកូនចៅ ព្រលឹមឡើងគេដេញឲ្យទៅទៀតហើយ ចឹងរត់ទៀតទៅ រទេះគោមួយបរចង់ងាប់ហើយ ។

ដានីៈ ចឹងពេលរត់ទៅហ្នឹង មុនពេលរត់មានប្រជុំផែនការថា យួនចូលមកសំភារៈត្រូវយើងយកទៅ ឬយើងត្រូវទុកណាយើងត្រូវកប់ឬយ៉ាងម៉េច?

មុំតៈ គ្មានអីទេ មានតែដាក់មួយរទេះគោទេ ។

ដានីៈ ដូចជាស្រូវអង្កប្រហុកប៉ឹចេងអី?

មុំតៈ ដាក់លើរទេះហ្នឹងទៅ បើនៅមន្ទីរធំៗគេមានរបស់គេ ។

ដានីៈ ចឹងខាងលើគេមានមកប្រជុំប្រាប់ថា យួនចូលមកយើងត្រូវសំភារៈអីយ៉ាងម៉េច?

មុំតៈ អាហ្នឹងបែកគ្នាអស់ហើយ ខ្ញុំរត់ជាមួយយាយថែម យាយថែម មានផែនការដាក់រទេះគោគេចឹងកងទ័ពនៅជួរមុខ យើងរត់ចឹងទៅវៀតណាមនៅខាងកើត ខ្សែត្រៀមគេហ្នឹង វាយបុកគ្នាមានឈ្នះអី គេតេអូរប្រាប់ប្រជាជនឲ្យដកថយ ។

ដានីៈ ចឹងលោកពូរត់ទៅជាមួយយាយថែម?

មុំតៈ រត់ទៅជាមួយយាយថែម បានមួយរយៈបែកគ្នារត់មកនៅនេះវិញ រត់មកនៅជាមួយតាវៀម វិញ ។

ដានីៈ នៅជាមួយតាវៀមវិញ?

មុំតៈ តាវៀម កាលហ្នឹងគាត់កាន់ខាងកងទ័ព ឲ្យធ្វើជាយោធាការពារប្រជាជន ។

ដានីៈ ហ្នឹងឆ្នាំណា ឆ្នាំរត់ហ្នឹង?

មុំតៈ ឆ្នាំ៧៩ ។

ដានីៈ ចឹង៧៩ពេលរត់យួនហ្នឹង?

មុំតៈ ហ្នឹងហើយ ។

ដានីៈ រត់មកដល់ត្រឹមណាទៅ?

មុំតៈ រត់តាមព្រំដែនហ្នឹងរហូតចឹងមក ឆ្នាំ៧៩ហ្នឹងដដែល ឆ្នាំ៧៩ ប្រហែលដើមឆ្នាំបានវាយគ្នាចឹងទប់មិនឈ្នះចឹងបានរត់ចូលដីថៃ ខ្ញុំកាលហ្នឹងអស់អីរលីងហើយរទេះគោចោលអស់រលីងហើយ ។

ដានីៈ ចឹងរត់ពីស្វាយហ្នឹងមកតាមព្រំដែនមកដល់ហ្នឹងបណ្តោយ?

មុំតៈ បាទ!មើលបានឡានដឹង មុនដំបូងមិនទាន់ដល់នេះទេ នៅស៊ីសុផុនខាងជើងទេណាស់ ឆ្លងមកមិនទាន់រួចទេ ព្រោះទ័ពវៀតណាមនៅពេញហ្នឹង នៅប៉ោយប៉ែតហ្នឹងឆ្លងមិនរួចទេ ដល់ហើយបានឡានថៃដឹក ចូលថៃ កាលហ្នឹងវាយជាមួយថៃ ដល់ហើយបានចរចារគ្នា ហៅប្រជុំអីថា

រឿងអតីតកាលយើងកាត់ចោលទៅ ឈប់វ៉ាយគ្នា ដល់ថៃដឹកយកទៅដាក់ភ្នំកាង៉ុកយើងនេះ ដាក់នៅហ្នឹងសុទ្ធព្រៃ ។

ដានី: ជំរំកាង៉ុក?

ម៉ុត: អត់មានជំរំទេ សុទ្ធតែព្រៃហ្នឹង ជំរំកើតនៅឆ្នាំ១៩៨៥នេះទេ ។

ដានី: ចឹងយ៉ាងម៉េចទៀតទៅ?

ម៉ុត: ពេលនេះទៅទ័ពគេមកចល័តការពារចឹងទៅណាស់ ការពារជួរមុខចឹង ហើយប្រជាជនចេះតែសសៀលតាមព្រំដែនចឹងទៅ តាមផ្លូវចាស់ពីដើម ផ្លូវ៧៩ ផ្លូវព្រំដែនយើងមានតើ តាមហ្នឹងចឹងទៅ ខ្លះបរទេះគោផ្ទុះមីន បរកាត់មីនគោន បងយន់ ហ្នឹងឈ្មោះ ហា ហ្នឹងប្រពន្ធគាត់ដាច់ដៃ ។

ដានី: បាទ ។

ម៉ុត: នៅហ្នឹងដល់ឆ្នាំ១៩៨០ កើតឡើងបានវ៉ាយគ្នាមួយសារទៀត បុកដល់ព្រំដែនបានរត់ចូលជំរំរត់ចូលដីថៃនៅបាក់បាង បានកាកបាទមក ។

ដានី: ចឹងយាយថែម គាត់មានរត់មកជាមួយដែលឬអត់ទេ?

ម៉ុត: អត់ទេ គាត់នៅខាងខត្តរនោះ ។

ដានី: គាត់នៅណា?

ម៉ុត: គាត់នៅខាងខត្តរ នៅខាងខត្តរមានជ័យនោះ ។

ដានី: ចឹងមកដល់ព្រំដែនបែកគ្នា?

ម៉ុត: បែកគ្នាអស់ហើយ ខ្ញុំមកនៅនេះបែកគ្នារហូតតាំងពីហ្នឹងមក ។

ដានី: ចឹងនៅក្នុងជំរំអីក៏អត់មានជួបគ្នាដែរ?

ម៉ុត: អត់ទេ អត់មានមកទេ ។

ដានី: ចឹងលោកពូពេលនៅជំរំហើយយ៉ាងម៉េចទៀតទៅ?

ម៉ុត: ខ្ញុំចូលជំរំ កាលហ្នឹងកាកបាទចិញ្ចឹម ។

ដានី: ចឹងទាំងក្រុមគ្រួសារប្រពន្ធកូនអីមកហ្នឹងដែរ?

ម៉ុត: បាទ! មកទាំងអស់ ។

ដានី: ចឹងតាវៀម អីគាត់រត់មកជាមួយដែរ?

ម៉ុត: បាទ! តាវៀម មកជាមួយគ្នាមក ។

ដានី: មកនៅក្នុង?

មុំតះ	តារៀម អត់មានមកនៅក្នុងជំរំទេ ជំរំរបស់កាកបាទនេះអត់មានមកនៅទេ មកនៅជំរំខ្មែរក្រហមដាក់ដោយឡែក ។

ដានីៈ	អាហ្នឹងគេហៅជំរំអីគេ?

មុំតះ	អាហ្នឹងគេហៅជំរំភ្នំដី ។

ដានីៈ	អាហ្នឹងជំរំខ្មែរក្រហម?

មុំតះ	បាទ! កូនភ្នំដីមួយខាងលិចនោះ ភ្នំនៅដីថៃនោះ ។

ដានីៈ	លោកពូមកនៅខាងកាកបាទក្រហម?

មុំតះ	បាទ! ខ្ញុំមកនៅបីទៅបួនខែទេ មកនៅជាមួយបងខ្ញុំ ជា ភួងភារម្យ ។

ដានីៈ	ជា ភួងភារម្យ ហ្នឹងត្រូវជាបងប្អូនរបស់ពូ?

មុំតះ	ឪពុកគាត់យកម្តាយខ្ញុំហ្នឹង ឪពុកគាត់ស្លាប់កាលឆ្នាំ៩៤ ។

ដានីៈ	ចឹងឪពុកម្តាយពូលែងគ្នាទៅ ក្រោយមកឪពុករបស់គាត់មកយកម្តាយពូ?

មុំតះ	បាទ! ទើបយក កាលឆ្នាំ៨៣ គាត់ចាស់ហើយ ។

ដានីៈ	បាទ! ចាស់ ចឹង ជា ភួងភារម្យ ហ្នឹងគាត់អាយុច្រើនជាងពូ?

មុំតះ	គាត់អាយុចូល៦៨-៦៩ហើយ ។

ដានីៈ	ចឹងពូនៅជំរំកាកបាទហ្នឹងបានតែប៉ុន្មានខែទេ?

មុំតះ	បានតែប៉ុន្មានខែ ។

ដានីៈ	ដល់ហើយចេញមកខាងណាទៀត?

មុំតះ	ដល់ខែ៧-៨ខ្ញុំចេញមកនៅជំរំភ្នំដីហ្នឹងតែម្តង កាលហ្នឹងជំរំ២៥០ តាកន គាត់នៅហ្នឹង ។

ដានីៈ	តាកន នៅហ្នឹង ខ្ញុំចង់ដឹងប្រវត្តិបន្តិច ចឹងនៅខាងនេះ តាកន មកគាត់មកនៅនេះឆ្នាំណា នី កន?

មុំតះ	នី កន កាលឆ្នាំ៧៩ឃើញគាត់មកនៅហ្នឹងរហូត ។

ដានីៈ	ចឹង នី កន មកគាត់មកនៅតាំងពីឆ្នាំ៧៩?

មុំតះ	បាទ! ជាមួយប្រជាជនទាំងអស់គ្នាហ្នឹង ។

ដានីៈ	ចឹងគេមកជាមួយប្រជាជនមកនៅជំរំភ្នំដីហ្នឹងដែរ?

មុំតះ	បាទ! គាត់មកនៅភ្នំដី ។

ដានីៈ	ចឹងមានជាកកើតកងទ័ពខាងយើងហ្នឹងចាប់ពីឆ្នាំណាមក?

មុំតះ	តាំងពី៧៩រហូត សុទ្ធតែកងទ័ពចាស់យើងតាំងពីកម្ពុជាប្រជាធិបតេយ្យ ។

ដានីៈ	ចឹងកាលហ្នឹងកងពលលេខប៉ុន្មាន?

មុំតៈ	កាលហ្នឹងមិនទាន់មានកងពលទេ ពេលក្រោយមកមេខ្លះគាត់ស្លាប់បាត់ទៅមេខ្លះចូលគ្នាអស់ទៅ ។ នៅជំរំអត់មានកងពលអីទេ គាត់មកចូលដីថៃអីហ្នឹង គាត់ល្អជាងគេ គេឲ្យគាត់ធ្វើមេ រហូតមកណាស់ មេវរសេនាធំចឹងមក ។

ដានី:	ចឹងកាលហ្នឹង នី កន គាត់នៅកងពល២៥០ចឹង?

មុំតៈ	កងពលធំ២៥០ ។

ដានី:	កងពលធំ២៥០?

មុំតៈ	កងពលតូច៣២០ ។

ដានី:	ចឹង៣២០មេពីណាគេ?

មុំតៈ	៣២០ហ្នឹង ជា ភូងភារម្យ មានតាបៃ, តាអៀន ។

ដានី:	តាបៃ ក្រុមប្រឹក្សាស្រុក?

មុំតៈ	ហ្នឹងហើយ ។

ដានី:	ចឹងតាហៀន នៅណា?

មុំតៈ	តាហឿន ស្លាប់បាត់ហើយ ច្រើនណាស់ ខ្មោចតាឈឹម ស្លាប់អស់ហើយ ។

ដានី:	តាឈឹម?

មុំតៈ	អឺ!

ដានី:	ប្រធានគេពីណាគេប្រធាន?

មុំតៈ	តាបៃ អនុ ។

ដានី:	តាហៀន?

មុំតៈ	តាហឿន ប្រធានជាមួយគ្នា កាលពីមុនតាហឿន ប្រធាន ដល់តាហៀន ស្លាប់ទៅគាត់ឡើងប្រធាន ។

ដានី:	ចឹងតាឈឹម?

មុំតៈ	តាឈឹម គាត់ជាសមាជិក ។

ដានី:	ហើយមានកងពលមួយទៀត កងពលរបស់តាពុធ?

មុំតៈ	អឺ ។

ដានី:	ចឹងកងពល៣២០នេះ ពីត្រឹមណាដល់ត្រឹមណា?

មុំតៈ	កងពល៣២០ វាយត្រឹមនេះទៅទល់មុខគ្នានៅម្តុំព្រៃធំ ម្តុំស្ទឹងអីហ្នឹង ។

ដានី:	ម្តុំស្ទឹងនៅណា នៅបវេលវិញ?

មុំតៈ	នៅបវេលហ្នឹង ខាងភ្នំសំពៅហ្នឹង ។

ដានី: ភ្នំសំពៅ?

ម៉ុត: បើកងពលតាពុធ នៅទន្លេសាបនោះហើយតាប៉ិន ហ្នឹងនៅខាងទន្លេសាបនោះ ។

ដានី: តាជាតិ?

ម៉ុត: គាត់ស្លាប់ហើយវាយគ្នាមុនដួចខ្លួនហ្នឹង វាយនៅបន្ទាយទី១ហ្នឹង ។

ដានី: ចឹងតាជាតិ ហ្នឹងកងពលវាយនៅណា?

ម៉ុត: អាហ្នឹងមកចំរុះគ្នាមកវាយ កាលឆ្នាំ១៩៩៨ វាយគ្នាបុកគ្នានៅម្តុំបន្ទាយទី១ ។

ដានី: វាយគ្នាឯងហ្នឹង?

ម៉ុត: វាយជាមួយខាងក្នុង ។

ដានី: វាយជាមួយខាងរដ្ឋាភិបាល?

ម៉ុត: ហ្នឹងហើយ ។

ដានី: មានស្លាប់ច្រើនទេ?

ម៉ុត: ស្លាប់ច្រើន ។

ដានី: គាត់ស្លាប់ដោយសារមូលហេតុអី?

ម៉ុត: គ្រាប់ផ្លោង មកពីខាងនោះមក ។

ដានី: ត្រូវគាត់?

ម៉ុត: បាទ ។

ដានី: តាជាតិ អនុគាត់មានពីណាទៀត?

ម៉ុត: ខ្ញុំមិនសូវស្គាល់ទេ ។

ដានី: តាគង់?

ម៉ុត: អើយ! តាជាតិ, តាគង់អីហ្នឹង ។

ដានី: ឥឡូវគាត់ទៅធ្វើខាងខេត្ត?

ម៉ុត: ហ្នឹងហើយឥឡូវគាត់ជាសមាជិកក្រុមប្រឹក្សាខេត្ត ។

ដានី: តាគង់ហ្នឹង?

ម៉ុត: មានតាគង់ តាអីខ្លះទេ ។

ដានី: ហ្នឹងនៅខាងកងពលហ្នឹងដែរ?

ម៉ុត: បាទ ។

ដានី: កងពលហ្នឹងនៅខាងកំរៀង?

ម៉ុត: កំរៀង កងពលតូច ។

ដានី៖ ចឹងកងពល៣២០នេះ?

ម៉ុត៖ កងពលតូចដែរ ។

ដានី៖ កងពលតូចដែរ នៅខាងភ្នំព្រឹកហើយខាងសំពៅលូន?

ម៉ុត៖ ខាងសំពៅលូនហ្នឹង ។

ដានី៖ ចឹងតាពុធនេះសំពៅលូន?

ម៉ុត៖ ហ្នឹងហើយគឺឡូ៩នេះ ទើបបាននៅព្រំដែនបានចែកភូមិគ្នានៅ កាលនៅជំរំភ្នំដីនៅជាមួយគ្នាទាំងអស់ហ្នឹង ។

ដានី៖ តែនៅតាមព្រំដែន កងពលតាពុធ នៅសំពៅលូន កងពលតារុំ នៅភ្នំព្រឹក ហើយកងពលនេះនៅកំរៀង ចឹងលោកពូពេលមកនៅភ្នំដី លោកពូមកនៅកងពល៣២០?

ម៉ុត៖ ខ្ញុំមកនៅជាមួយគាត់ ។

ដានី៖ ពូធ្វើកងទ័ព?

ម៉ុត៖ អត់ទេ ធ្វើប្រជាជន នៅកាន់សេដ្ឋកិច្ចជាមួយគ្រួសារយោធា ។

ដានី៖ កាន់ខាងសមរភូមិក្រោយ ដឹកជញ្ជូនកងពល ពូធ្វើប្រធាន?

ម៉ុត៖ អត់ទេ ខ្ញុំជាសមាជិកគេ ។

ដានី៖ ចឹងពីណាគេប្រធាន?

ម៉ុត៖ តាចក់ មានអីនៅស្រុកបែបស្លាប់បាត់អស់ហើយ ។

ដានី៖ ឆ្នាំណាដែលចូលកងពល៣២០?

ម៉ុត៖ ឆ្នាំ៨៥ ។

ដានី៖ ចឹងឆ្នាំ៨៥បានចូល?

ម៉ុត៖ បាទ ។

ដានី៖ ពីមុនអត់ទេ?

ម៉ុត៖ ពីមុននៅខាងប្រជាជន ។

ដានី៖ មុនឆ្នាំ៨៥មានកងពល៣២០ដែលអត់ មុនតាំងពី៧៩-៨១-៨២អី?

ម៉ុត៖ អត់មានទេ ។

ដានី៖ អត់មានទេ?

ម៉ុត៖ បង្កើតនៅឆ្នាំ៧៩-៨០ ។

ដានី៖ បង្កើតឆ្នាំ៧៩-៨០ ប៉ុន្តែ?

ម៉ុត៖ ៨០-៨១ហ្នឹង ។

ដានី៖	៨០-៨១ តែពូកាលហ្នឹងមិនទាន់ចូលទេ.?

ម៉ុត៖	ខ្ញុំអត់ទេ ខ្ញុំនៅប្រជាជន ខ្ញុំទើបចូលឆ្នាំ៨៥ហ្នឹង ហើយឪម៉ែខ្ញុំចាស់ៗហ្នឹង បងគាត់ឲ្យមកនៅជាមួយទៅណាស់ ។

ដានី៖	ចឹងតាកន គាត់កងពល២៥០ហើយអនុគាត់ពីណាគេ?

ម៉ុត៖	អនុ តាកន ខ្ញុំមិនសូវស្គាល់ដែរ តាកន តា៦៣ ឈ្មោះតាសារឿន ។

ដានី៖	តាសារឿន?

ម៉ុត៖	គាត់ស្លាប់បានហើយ ស្លាប់ឆ្នាំ៩៨នោះ ។

ដានី៖	ហ្នឹងអនុគាត់?

ម៉ុត៖	បាទ ។

ដានី៖	តាកន គាត់មានឈ្មោះអីខ្លះ?

ម៉ុត៖	ខ្លះហៅ តាគិន ទៅ តាកន ហ្នឹង តាកិន ។

ដានី៖	គាត់មានឈ្មោះ ហៅជាលេខដែលអត់?

ម៉ុត៖	មានលេខខ្ញុំមិនចាំ ។

ដានី៖	ចឹងពេលចូលឆ្នាំ៨៥ ចូលក្នុងកងពល៣២០ពូនៅក្នុងដីថៃ ឬមួយដីខ្មែរ?

ម៉ុត៖	ដីខ្មែរ កាលហ្នឹង កាលនៅដីថៃ ដល់ឆ្នាំ៩៣ បានមកនៅដីខ្មែរ ។

ដានី៖	ចឹងឆ្នាំ៩៣បានចូលមកនៅដីខ្មែរ?

ម៉ុត៖	បានសមាហរណ៍កម្មមានបីភាគីត្រូវគ្នាណាស់ កាលហ្នឹងគេដឹកអ្នកជំរំទៅស្រុកវិញអស់ ។

ដានី៖	ចឹងកាលពីឆ្នាំ៨៩-៩០?

ម៉ុត៖	អូរឆ្នាំ៩០មក កាល៩៣ត្រូវគ្នាហ្នឹង ឆ្នាំ៩០ចូលមកបណ្ដើរៗហើយធ្វើភូមិធ្វើអីនៅ ។

ដានី៖	ចឹងឆ្នាំ៩០ចូលមកនៅណាដំបូង?

ម៉ុត៖	ចូលមកនៅហ្នឹងតែម្ដង តែគ្រួសារមិនទាន់ដឹកមកទេ នៅជំរំដដែល ដល់ឆ្នាំ៩៣បានមក ៩៣ គេដឹកអ្នកជំរំចេញអស់ ។

ដានី៖	ចឹងឆ្នាំ៩០ចូលមកដល់ដំបូងមកនៅភូមិណាទៅ?

ម៉ុត៖	នេះនៅក្រោយមាត់អូរនេះ ។

ដានី៖	ចឹងជាប់មាត់អូរហ្នឹង?

ម៉ុត៖	បាទ ។

ដានី៖	ចឹងចូលមកដល់ដំបូងមានស្ថានភាពបែបម៉េចទៅ?

ម៉ុត៖	ចូលមកដំបូងស្ងាត់ឈឹង សុទ្ធតែមីន ដើរដោះតែមីន ។

ដានី៖ ចឹងអត់ខ្លាចទេ មានមីនចឹង?

ម៉ុត៖ អត់អីទេ អត់ខ្លាច ដើរដោះមីនអីទៅ ។

ដានី៖ មីនគេដាក់នៅលើឬគេដាក់ក្នុងដី?

ម៉ុត៖ មីនខ្លះដាក់លើ មីនខ្លះដាក់កប់ដីចោលទៅណាស់ អ្នកដាក់ចេះតែដាក់ទៅខ្លះបានកប់ទៅ ។

ដានី៖ ចឹងបើអាកប់យើងមើលឃើញដែរ?

ម៉ុត៖ កប់នៅនេះដាក់ខ្សែគេ ដូចថាបីជួរចឹង ក្នុងមួយជួរប្រវែងមយយម៉ែត្រមួយៗចឹងទៅណាស់ មានដាក់តាមហ្នឹង ។

ដានី៖ ចឹងយើងដោះដែលអត់មានគ្រោះថ្នាក់អីទេ?

ម៉ុត៖ អត់មានអីទេ មានគ្រោះថ្នាក់ប៉ុន្មាននាក់ដែលហ្នឹង ហ្នឹងជាន់មីនស្លាប់អាធំនោះ បើមីនស្គរចិន បុិនៗនេះទេ ហ្នឹងជាន់ដាច់ត្រឹមនេះទេ មីនរបស់សូវវៀត មីនខ្វែងហ្នឹង ហើយប្រណាកចឹង ដែលអត់មានរស់ទេ ដាច់ដល់ក្រលៀនតែម្តង មីនប្រណាករបស់វៀតណាមយកមកដាក់ ។

ដានី៖ បាទ ។

ម៉ុត៖ អាហ្នឹងវាធ្វើដូចជាប្រអប់យើងចឹង ប្រអប់មានពណ៌វាចឹងដាក់កឹបហ្នឹងយើងជាន់ទៅរបូតកឹប សំណរហ្នឹងវាយភីង ខ្ញុំទើបមកប្រជាជនទើបមករកស៊ីនឹងធឹងបានសុខសប្បាយស្រួលទើបផ្តាច់ ខ្លួនឆ្នាំ៩៦ហ្នឹង ។

ដានី៖ ចឹងកាលឆ្នាំ៩០មកដោះមីនហ្នឹង ពេលហ្នឹងគ្រួសារមានមកជាមួយធ្វើផ្ទះអីនៅ?

ម៉ុត៖ នៅទីទេ ដល់វាវបានមួយខែពីរខែ គេស្អាតហើយបានយកគ្រួសារមក ។

ដានី៖ ចឹងបានធ្វើផ្ទះទៅ?

ម៉ុត៖ បាទ ។

ដានី៖ ចឹងវាវស្អាតចឹងទៅ អាផ្សេងទៀតយើងមិញហ៊ានដើរទៀតទៅ?

ម៉ុត៖ យើងដឹងថា កាល«ក៥»ហ្នឹងដាក់តែមួយខ្សែ ដូចថាទទឹង៥០ហ្នឹង ដាក់៥០ម៉ែត្រភ្លឹងចឹងទៅ កាលហ្នឹងនៅស្អាមដែលហ្នឹងទើបដាក់ថ្មីៗដែរ ។

ដានី៖ ដាក់ថ្មីៗដែរ?

ម៉ុត៖ បាទ ។

ដានី៖ នៅស្អាមកាប់ព្រៃចឹងទៅ?

ម៉ុត៖ ហ្នឹងហើយ អាខ្លះដាក់ចាស់ដែរ តែគេដឹងខ្សែ មីនខាងរដ្ឋកម្ពុជាមិនដូចខាងខ្មែរក្រហមដាក់ទេ មីនខាងខ្មែរក្រហមដាក់មិនដឹងទិសតំបន់អីណាទេ ។

ដានី៖ ចឹងចេះតែដាក់តរទៅបាត់ទៅ?

ម៉ុតៈ ដូចថា អូនឯងមកស្នាក់នៅតាមក្រុមហ្នឹង មកស្នាក់នៅមួយក្រុមហ្នឹង កន្លែងនៅហ្នឹងដាក់ការពារ អូនឯងចេញទៅអត់ដោះចេញ អ្នកចូលមកនៅថ្មីទៀតដើរជាន់គ្នានិងឯងអត់ដឹង ។

ដានីៈ ជាន់មីនគ្នាឯងហ្នឹង?

ម៉ុតៈ ជាន់មីនគ្នាឯងហ្នឹង ចឹងពេលចេញទៅមានពីណាដោះ មីន៦៩ហ្នឹងទុកចោលហ្នឹង ។

ដានីៈ ចឹងដាក់ជាប់ជាន់នៅហ្នឹងទៅ?

ម៉ុតៈ អឺ ។

ដានីៈ ចឹងពេលដោះមួយខែ្សខាងហ្នឹងអស់ទៅខាងនេះអត់មានអីទេ?

ម៉ុតៈ អត់មានអីទេ ដាក់តាមព្រំដែនខាងក្នុង មីនមានតាមខ្សែ ។

ដានីៈ ចឹងដោះបានមួយខ្សែចឹងទៅបាននាំកូនប្រពន្ធមកធ្វើផ្ទះនៅទៅ ចឹងដំបូងបំផុតនៅតាមមាត់អូរហ្នឹងទេ?

ម៉ុតៈ ដល់ពេលចឹងទៅបានមានបីភាគីឆ្នាំ៩៣-៩៤បានមេធ្វើផ្លូវលំហ្នឹង ។

ដានីៈ ចឹងផ្លូវហ្នឹងដំបូងឈូសហ្នឹងតែម្តង?

ម៉ុតៈ បាទ ។

ដានីៈ ចឹងចាប់ពីឆ្នាំ៩៣-៩៤?

ម៉ុតៈ បាទ ។

ដានីៈ ចឹងដល់ពេលស្រួលមែនទែនឆ្នាំណា ដែលយើងចាប់ផ្តើមអភិវឌ្ឍន៍ស្រុកទេស?

ម៉ុតៈ អភិវឌ្ឍន៍ស្រុកទេស តាមពិតទៅពេលផ្តាច់ខ្លួនហ្នឹងតែម្តងឆ្នាំ៩៦ហ្នឹង មានផ្ទះថ្ម ផ្ទះធំចឹងទៅពីមុនមានធំដែរ នោះផ្ទះជនាន់ហ្នឹង មានធ្វើមួយៗ ។

ដានីៈ ចឹងដំបូងពូនៅតាមមាត់អូរ ដោះមីនអីទៅ?

ម៉ុតៈ បាទ ។

ដានីៈ ចឹងដល់ពេលឆ្នាំ៩៦ហ្នឹង ចាប់ផ្តើមកើតផ្ទះធំៗតែម្តង?

ម៉ុតៈ មានកើតដែរ តែកើតវាមិនសូវច្រើន ដូចឥឡូវនេះ រកស៊ីលើកមុនគេដកមួយសារហើយហ្នឹងគេដើរដករបស់របរមួយសារហើយហ្នឹង ។

ដានីៈ ចឹង?

ម៉ុតៈ បាទ! មុនផ្តាច់ខ្លួនហ្នឹង ចឹងបានបាស់ឈុលហ្នឹង អ្នកណាមានរទេះគោក៏ដក ឡានក៏ដកដកយកទៅដាក់មួយដុំ ។

ដានីៈ មិញចឹង?

ម៉ុតៈ គេមិនឲ្យមាន គេថាបើមានចឹងអត់មានតស៊ូវាយខ្មាំងកើតទេ ដីចម្ការក៏គេដក គេដកគេចែកម្នាក់តែបីរ៉ៃ ។

ដានីៈ ដល់ពេលដកចឹងទៅប្រជាជនអត់ព្រមទេ?

ម៉ុតៈ អត់ព្រមបាស់ឈុលទៅ ។

ដានីៈ ដល់ចឹងគាត់ទៅនោះវិញទៅ?

ម៉ុតៈ កាលហ្នឹងមិនទាន់ដកទេ ដល់បាស់ឈុលចឹង តាសុន សេន ប្រជុំ ចេះចុះទៅ កាលពីដើមមិនដែលឃើញមុខតាសុន សេន ទេ ដល់ឃើញគ្រួសារប្រជាជនកងទ័ពបាស់ចឹងទៅបានឃើញគាត់មកប្រជុំ ។

ដានីៈ កន្លែងតាកន?

ម៉ុតៈ ចុះកាលហ្នឹងវាជ្រុលហើយ ។

ដានីៈ ចឹងគាត់ហៅទៅប្រជុំមានទៅដែលអត់?

ម៉ុតៈ ខ្ញុំទៅជួបមុខម្តងមើល កាលពីមុនមិនដែលជួប ។

ដានីៈ ចឹងឈ្មោះភូមិអីហ្នឹងគេចាប់ផ្តើមដាក់តាំងពីពេលណាមក ដូចថាឈ្មោះទួលខ្ពស់អីចឹង?

ម៉ុតៈ ហ្នឹងដាក់ជំនាន់ ផ្តាច់ខ្លួនហើយបានចងក្រងជាភូមិជាក្រុមដាក់ជំនាន់ហ្នឹង ។

ដានីៈ លោកពូជាអ្នកផ្តើមគំនិតដាក់ ឬមានខាងណា?

ម៉ុតៈ មិនមែនទេ មេឃុំមេអី ដើរពិនិត្យជាមួយភូមិទាំងអស់គ្នា ដូចថាភូមិគគីរ កាលពីដើមភូមិហ្នឹងមានដើមគគីរច្រើនចឹងទៅណាស់ ។

ដានីៈ បាទ ។

ម៉ុតៈ ភូមិស្តៅ មានស្តៅ ភូមិទួលខ្ពស់ ព្រោះមានដីខ្ពស់ជាងគេ ។

ដានីៈ ចឹងនេះគេហៅភូមិទួលខ្ពស់?

ម៉ុតៈ បាទ ។

ដានីៈ ចឹងមុំផ្ទះតារៀម គេហៅភូមិអីគេ?

ម៉ុតៈ ហ្នឹងភូមិទួលខ្ពស់ហ្នឹងហើយ ។

ដានីៈ ចឹងតារៀម នៅក្នុងភូមិទួលខ្ពស់?

ម៉ុតៈ ភូមិទួលខ្ពស់ចាប់ពីក្លោងទ្វារចូលសាលារៀនហ្នឹង ។

ដានីៈ តារៀម ប្រពន្ធគាត់ឈ្មោះអី?

ម៉ុតៈ ឈ្មោះ សុខា ។

ដានីៈ ចឹងគាត់ឋិតនៅភូមិទួលខ្ពស់ ឃុំភ្នំព្រីក ស្រុកភ្នំព្រីកហ្នឹងដែរ?

មុំត: បាទ ៗ

ដានី: ចឹងចាប់ផ្ដើមបង្កើតភូមិអីចឹងទៅបានគេបញ្ជូនទៅខាងក្រសួងមហាផ្ទៃចឹងទៅ?

មុំត: បាទ ៗ

ដានី: ចឹងលោកពូយើងចាប់ផ្ដើមអភិវឌ្ឍន៍ខ្លាំងដូចថាមានអី ផ្ទះធំៗមានថ្នល់អី ព្រៃឈើបាត់អស់តាំងពីឆ្នាំណាមក បើតាមលោកពូមានប្រសាសន៍ថា ឆ្នាំ៨៩-៩០ហ្នឹងសុទ្ធតែព្រៃ?

មុំត: ឆ្នាំ៧៣-៧៤-៧៥ហ្នឹង មិនទាន់ផ្ដាច់ខ្លួនហ្នឹងព្រៃវាលហើយ ត្រឹមភ្នំនេះ ហើយទៅកើតក៏វាដែល វាដុះៗកាលហ្នឹង ៗ

ដានី: ឆ្នាំ៩៤-៩៥?

មុំត: ហ្នឹងហើយដល់ពេលផ្ដាច់ខ្លួនឆ្នាំ៩៦ហ្នឹង ខាងរដ្ឋាភិបាលអនុញ្ញាតឲ្យបីឆ្នាំហ្នឹង កាប់ខ្លាំងអ្នកពីក្នុងក៏មកដែរ អ្នករកស៊ីឈើហ្នឹង ថៃអីហ្នឹង ៗ

ដានី: ចឹងកាលយើងផ្ដាច់ខ្លួនដំបូងឆ្នាំ៩៦ ខាងរដ្ឋាភិបាលអនុញ្ញាតឲ្យយើងស្កាព្រៃបីឆ្នាំ?

មុំត: បាទ ៗ

ដានី: រកស៊ីបីឆ្នាំ?

មុំត: ហ្នឹង កាប់ធ្វើផ្ទះអីហ្នឹង កាលពីមុនមានពីណាហ៊ានធ្វើ កាលនៅខ្មែរក្រហមកាន់កាប់ អ្នកឯងហ៊ានកាប់ព្រៃ តែគេដឹងប៉ូលីសចាប់បានដាប់គុក ៗ

ដានី: ចឹង?

មុំត: ចុះគេទោសមរភូមិឯងនៅធ្វើ ៗ

ដានី: ចឹងជំនាន់៩០ដាងហើយមានគុកទៀត?

មុំត: ហឺ!មាន ៗ

ដានី: គុកនៅណា?

មុំត: គុកនៅកន្លែង៣២ ៗ

ដានី: គុក៣២ខ្ញុំឮគេថាគុកចម្ការល្ហុងហ្នឹង?

មុំត: ហ្នឹងហើយ គុកចម្ការល្ហុងហ្នឹងគេចាប់បានយកទៅឲ្យកាប់ព្រៃនៅហ្នឹង ៗ

ដានី: តាអី?

មុំត: តាចាន់ ៗ

ដានី: ចឹងតាចាន់ កាន់កាប់នៅហ្នឹង?

មុំត: ហ្នឹង ៗ

ដានី: ចឹងលោកពូធ្លាប់រស់នៅតាំងពីបូនមកដល់សព្វថ្ងៃហ្នឹង ពូឃើញថាតាំងពីជំបូងមកដល់ឥឡូវមាន ការប្រែប្រួល មានការអភិវឌ្ឍន៍ឬមានការវិជ្ជមានអវិជ្ជមានយ៉ាងម៉េចខ្លះ?

ម៉ុត: ខុសគ្នាច្រើនណាស់ កាលពីដើម មិនទាន់ផ្តាច់ខ្លួនចូលជាមួយរដ្ឋកម្ពុជារកស៊ីបានដែរ តែបាន ត្រឹមម៉ារស់ កាលហ្នឹងខ្វះខាតអី កាលមុនគេផ្តាច់ជំនួយអស់ទៅគិតរកស៊ីខ្លួនឯង ដល់ចឹងទៅ រដ្ឋជួយបន្តិចៗដល់រដ្ឋជួយតិចៗចឹងទៅ ដល់យើងធ្វើខ្លាំងខុសទៀត។ កាលហ្នឹងវាអត់អ្នកទៅ មុខ ដល់ហើយបានគេដកឥវ៉ាន់អីអស់ ដកទៅមុខមានអីស៊ី ដល់ហើយបានផ្តាច់ខ្លួនចូលមក បានប្រែប្រួលរហូតចឹងមកតាំងពីឆ្នាំ៩៦មក យើងមានសិទ្ធសេរីភាពពេញលេញហើយ រដ្ឋា ភិបាលបើកចំហរឲ្យរកស៊ីហើយ។ ចឹងមានបងប្អូនខ្លះបានសប្បាយរីករាយបានទៅជួបជុំបង ប្អូនគ្រួសារនៅស្រុកនោះឆ្នាំ៩៧-៩៨ហ្នឹង។ ខ្លះណាបានទៅស្រុកទៅអី ទៅលេងស្រុកច្រើន ណាស់ កាលជំនាន់ហ្នឹង ចឹងបានជាមានបងប្អូនយើងមកនៅនេះ នៅនេះភាគច្រើនមានបង ប្អូនមកពីក្នុងមករស់នៅ អ្នកនៅនេះមានភាគតិចណាស់ អ្នកមូលដ្ឋាននេះ ខ្លះមានកូនមានចៅ ទៅ មានបងប្អូនការកូនចៅ បងប្អូនកូនក្មួយមកនៅជាមួយគ្នាទៅ។

ដានី: ព្រោះឃើញនៅនេះ ពេលមានសមាហរណ៍កម្មមក មានសក្តានុពលឃើញថា ដីនៅទូលាយ ដីមានជីជាតិ ចឹងនាំគ្នាមករកស៊ីមកធ្វើចម្ការនេះវាគ្រាន់បើជាងនៅស្រុក?

ម៉ុត: បាទ! នៅនេះចឹងឲ្យតែអ្នកប្រឹងរក ការហូបចុកអីរកបានតើ ខ្លះមកនេះអត់មានដីមួយគ្រប់តែ រស់ រស់ដោយសារអី ដោយសារគាត់ប្រឹងប្រែង អ្នកណាក៏មានម៉ូតូជិះដែរ មានទូរស័ព្ទគ្រប់ គ្នា ចឹងអត់មានការវេទនាអីខែសម្រាកកាប់ដំឡូង ដាំខ្លួនឯងបន្តិចបន្តួចចឹងដីមួយរ៉ៃពីរហើយដើរ ស៊ីឈ្នួលយកលុយចាយទៅ ដល់ខែអស់ដំឡូងហ្នឹង បន្តិចទៀតដល់ខែដាំទៀតហើយ។ ចឹងដល់ខែដាំបាញ់ថ្នាំអីចឹងទៅ ចេះតែតរហូត តែឲ្យអ្នកខស្សាហ៍អ្នកខ្ជិលខ្ញុំមិនដឹងទេ។

ដានី: បាទ។

ម៉ុត: ហើយចេះគ្រប់គ្រងថវិការហ្នឹង កុំចាយវាយ មាន។

ដានី: ខ្ញុំភ្លេចសួរលោកពូ តាប៉ូ ហ្នឹងគាត់ស្លាប់ហើយ?

ម៉ុត: ស្លាប់ហើយ ស្លាប់ពីរឆ្នាំហើយ។

ដានី: ចឹងតាឈុន?

ម៉ុត: តាឈុនក៏ស្លាប់ដែរ តាឈុន ស្លាប់តាំងឆ្នាំ៩៣នោះ។

ដានី: ចឹងដោយសារលោកពូធ្លាប់រស់នៅឆ្លងកាត់តាំងពីតូចមក ហើយសម័យសង្គ្រាម រដ្ឋប្រហារ ហើយ សម័យបីឆ្នាំ ពូយល់ឃើញថា យ៉ាងម៉េចដែរ ការរស់នៅក្នុងរបបបីឆ្នាំ ឆ្នាំ៧៥-៧៩?

មុ៉តៈ	របបបីឆ្នាំ កាលរស់នៅដូចថា ភាពធ្ងឹត ធ្វើអីមិនបានសប្បាយនិងគេ ខំតស៊ូមកតាំងពីឆ្នាំ ៧០មកថា ថាលន់ នល់ វាក្បត់ជាតិ ថាសម្តេចឪយើង យើងថាខំទាមទារឲ្យប្រទេសយើង បានរីកចំរើន តែដល់ធ្វើទៅវាប្រែក្លាយទៅជាចិន កងទ័ពបាក់ទឹកចិត្តភាគច្រើន ។

ដានី:	ចិនកងទ័ពបាក់ទឹកចិត្តភាគច្រើន?

មុ៉តៈ	ហ្នឹង បាក់ទឹកចិត្តម៉េច ដូចថាកើតបក្សកុំម្មុយនីស្តចិនទៅ អាខ្លះណាវាខំតស៊ូខំជាក់ស្តែង ហើយ ខ្លះណាវរសេនាធំដល់ពេល ដូចថា ស្រឡាញ់នារីម្នាក់មានបងធ្វើទាហាននៅតំបន់លន់ នល់ ចិនទៅតំបន់ខ្មាំងជាប់និន្នការគេចាប់ឆ្កាដកចេញទៅ ។

ដានី:	បាទ ។

មុ៉តៈ	ចិនទៅគ្នាបាក់ទឹកចិត្ត ។

ដានី:	ចិនប្រៀបធៀបមើលលោកពូធ្លាប់ឆ្លងកាត់?

មុ៉តៈ	ដូចខ្ញុំ ឪខ្ញុំគាត់ធ្វើជំទប់ទី១ ខ្ញុំអត់មានបានធ្វើការអីទេធ្វើតែមហាជន គេឲ្យធ្វើមេភូមិ ទៅណា ក៏គេមិនសូវរាប់ ។ បើថាអ្នកមិនសូវចេះល្ងង់ពីដើម ពីសង្គមចាស់មិនដែលធ្វើអីហ្នឹងសុទ្ធតែ ឡើងធ្វើអ្នកធំហើយ ថារកអ្នកល្ងង់ធ្វើ កំចាត់អ្នកចេះចោល ។

ដានី:	ដោយសារលោកពូធ្លាប់ឆ្លងកាត់មកអីចឹង ប្រៀបធៀបមើលរបបពាឆ្នាំ ហើយក្រោយមក ខាងណាស្រួលជាង?

មុ៉តៈ	របបពាឆ្នាំ ក្រោយមក ម៉េចស្រួលដូចរបបយើងឥឡូវនេះ របបឥឡូវនេះរបបសេរី មិនដូច ជំនាន់កុំមុយនីស្តនិយម ខ្ញុំធ្លាប់រស់នៅសង្គមនិយាយមានសិទ្ធិសេរីភាព ខ្ញុំនៅក្មេងបុណ្យទាន ណាក៏ខ្ញុំដើរបានដែរ ការរកស៊ីអត់មានខ្វល់ ឥឡូវដូចហ្នឹងអីចឹង ដូចសង្គមនិយម ឥឡូវខ្ញុំចង់ ទៅស្រុកស្មានមាណ ខ្ញុំចង់ដើរទៅណាស្មានមាណ សិទ្ធិសេរីភាពអត់បិទទេ កុំឲ្យយើងដើរធ្វើ អំពើអាក្រក់ហ្នឹងក្រែងលោវាខុសច្បាប់ ។

ដានី:	កាលពីម្សិលមិញខាងតុលាការកាត់ទោសមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហម គេប្រកាសសាលក្រម កាត់ទោសនួន ជា, ខៀវ សំផន ជាប់គុកអស់មួយជីវិត តាមយោបល់លោកពូ?

មុ៉តៈ	តាមយោបល់គំនិតខ្ញុំវាសមស្របកំហុសដែលគាត់ធ្វើ គេមិនសម្លាប់គាត់គ្រាន់បើ គ្រាន់គេ ដាក់គុកមួយជីវិត ហ្នឹងវាសមស្របហើយទង្វើដែលគាត់ធ្វើ កុំថាគាត់មិនដឹងជំនាន់ហ្នឹងនោះ ដូចតាប៉ុល ពត មកទស្សនកិច្ចនៅស្វាយគាត់ដឹងហើយប្រជាជនធ្វើការនៅនេះ គាត់ដឹងថា អត់បាយ អត់ទឹក ។

ដានី:	តាប៉ុល ពត គាត់ធ្លាប់មកទស្សនកិច្ចនៅស្វាយដែរ?

មុ៉តៈ	តាមតំបន់ ។

ដានី៖ តាទួន ជា?

ម៉ុត៖ ធ្លាប់មកទាំងអស់ ទៅអង្គរវត្តឃើញ តែជនទាន់ហ្នឹងគេចេះណាស់ ឆ្នាំ៧៥-៧៩ប្រជាជនមាន សាច់មានឈាមអី គេកាត់ក្រណាត់ប្រដឹបកាត់ឲ្យស្ងៀកដូចកុកសអីចឹង ដល់ពេលថាហ៎ គណៈមជ្ឈិមបក្សមកទស្សនៈកិច្ចតាមផ្លូវហ្នឹង គេឲ្យប្រជាជនដែលស្គមៗដើរចេញអស់ហើយ អត់ឲ្យឃើញទេ ឲ្យជម្ងៀសចេញឲ្យអស់ ឲ្យតែកម្មាភិបាលណាដែលស្អាតកិច្ចការនៅហ្នឹង កាន់កាំបិត កាន់ចបនៅក្បែរផ្លូវឡានគេទៅហួសវីង ជនទាន់ហ្នឹងចឹងឯង។

ដានី៖ អីចឹងកាលទំនប់ត្រពាំងថ្មអីមានតាប៉ុល ពត, តាទួន ជា មក?

ម៉ុត៖ ហ្នឹងខ្ញុំទៅលើក ប្អូនខ្ញុំអាពៅទៅលើកទំនប់ត្រពាំងថ្ម។

ដានី៖ មានតាៗគាត់ទៅទស្សនៈកិច្ច?

ម៉ុត៖ ទៅមិនអត់ទេ តែខ្ញុំមិនស្គាល់ដឹង តែខ្ញុំឃើញឡាន ឃើញគេប្រាប់ថាបងប្អូនប្រជាជនកុំឲ្យធ្វើការក្បែរផ្លូវជាតិរញ៉េរញ៉ៃអី មេធំមកហើយ មួយសន្ទុះម៉ោង១០-១១ឃើញឡានសុទ្ធតែម៉ាកសីដេសបរ៨-១០ឡាន ដឹកភ្ញៀវទៅ។

ដានី៖ លោកពូខ្ញុំអរគុណច្រើន ដែលផ្ដល់បទសម្ភាសន៍ខ្ញុំជាងមួយម៉ោងនេះ អរគុណច្រើន។

ម៉ុត៖ បាទ!

ចប់